## មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

## វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

# កំណត់ហេតុកិច្ចប្រជុំខប់សែលឡឹម លើកទី ២២

# យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

# ថ្ងៃពុធ ទី២១ ខែមីនា ឆ្នាំ២០០៧

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme**

**របៀបវារៈនៃកិច្ចប្រជុំ**

០១. ការពិនិត្យឡើងវិញនូវការកំណត់ហេតុកិច្ចប្រជុំខប់សែលឡឹមលើកទី២១ ដែលបានធ្វើឡើងកាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧

០២. ការចែករំលែកព័ត៌មានទូទៅជុំវិញការរៀបចំការបោះឆ្នោត-ការបង្ហាញពីរបាយការណ៍ចុះសិក្សាស្រាវជ្រាវសំរាប់រៀបចំកិច្ចប្រជុំខប់សែលប្រ៊មនៅតំបន់ទី ៩ ក្នុងខេត្តកំពង់ធំ ខេត្តព្រះវិហារ កាលពីថ្ងៃទ០៥-០៨ ខែមីនា ឆ្នាំ២០០៧

០៣. ការអប់រំករណីពិការភាព និង ការងារបោះឆ្នោត

០៤. ករណីដែលនៅសេសសល់មួយសប្តាហ៍មុនការបោះឆ្នោត

០៥. សេចក្តីផ្សេងៗ

## ០១.ការពិនិត្យឡើងវិញនូវកំណត់ហេតុកិច្ចប្រជុំខប់សែលឡឹម លើកទី ២១ ដែលបានធ្វើឡើងកាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧

លោក **ឱក សេរី** *សោភ័ក្តិ* ទីប្រឹក្សានៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ( *វបសអ* ) និងជាអ្នកសំរបសំរួលយន្តការខប់សែល បានស្វាគមន៍ និងថ្លែងនូវអំណរគុណចំពោះអង្គប្រជុំទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំខប់សែលឡឹមលើកទី ២២ នៃយន្តការខប់សែលដំណាក់កាលទី ២ នេះ ។ លោកបានស្នើយោបល់អង្គប្រជុំលើរបៀបវារៈកិច្ចប្រជុំខប់សែលឡឹម លើកទី ២២ និងអនុម័តកំណត់ហេតុកិច្ចប្រជុំខប់សែលឡឹមលើកទី ២១ យកជាផ្លូវការ ។

## ០២. ការចែករំលែកព័ត៌មានទូទៅជុំវិញការរៀបចំការបោះឆ្នោត - ការបង្ហាញពីរបាយការណ៍ចុះសិក្សាស្រាវជ្រាវសំរាប់រៀបចំកិច្ចប្រជុំខប់សែលប្រ៊មនៅតំបន់ទី ៩ ក្នុងខេត្តកំពង់ធំ និង ខេត្តព្រះវិហារ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧

ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គជប បានលើកឡើងចំណុច ៥សំខាន់ៗ ទាក់ទងនឹងការបោះឆ្នោត ។ **ទី១** គឺការផលិតសំភារៈ ការដឹកជញ្ជូន និង ការបែងចែករហូតមកដល់ពេលនេះ គជប បានផលិតសំភារៈសំរាប់ការបោះឆ្នោតចប់សព្វគ្រប់ ហើយរួមទាំងសន្លឹកឆ្នោតបញ្ជីឈ្មោះអ្នកបោះឆ្នោតក៏ដូចជាទឹកខ្មៅលាងមិនជ្រះដែលទិញមកពីប្រទេសឥណ្ឌា ត្រាសំងាត់សំរាប់ ការិយាល័យបោះឆ្នោត ហើយការដឹកជញ្ជូនសំភារៈទាំងនេះទៅតាមបណ្តាខេត្ត ។ **ទី២** អំពីបញ្ហាបណ្តុះបណ្តាល និង ការអប់រំសាធារណៈជន ការបណ្តុះបណ្តាលសំរាប់ដំណាក់កាលនៃការបោះឆ្នោត រាប់សន្លឹកឆ្នោត និង ការប្រកាសលទ្ធផលនៃការបោះឆ្នោតបានធ្វើរួចរាល់ ហើយនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និង ថ្នាក់ឃុំសង្កាត់ដែលមានសមាជិកចំនួន ៨១២០នាក់ ហើយបញ្ហានៅ ចំពោះមុខនេះគឺការបណ្តុះបណ្តាលដល់មន្ត្រីការិយាល័យបោះឆ្នោតដែលឥលូវនេះកំពុងស្ថិតក្នុងដំណាក់កាលនៃការជ្រើសរើស ។ ចំពោះការអប់រំដល់សាធារណៈជន គជបបានផលិតសំភារៈអប់រំសាធារណៈជនច្រើន និង ឯកសារសំរាប់ការបណ្តុះបណ្តាលច្រើន ។ សំភារៈ មួយចំនួនផលិតដោយ គ.ជ.ប និង សំភារៈមួយចំនួនទៀតរៀបចំឡើងដោយ UNDP ហើយនៅក្នុងនោះមានឯកសារមួយ ដែលសំខាន់ដែលការបោះឆ្នោតកន្លងមកមិនដែលរៀបចំនោះគឺឯកសារស្តីពីការបណ្តុះបណ្តាលការងាររៀបចំការបោះឆ្នោត ដែលបាន ចាក់ផ្សាយយ៉ាងទូលំទូលាយតាមរយៈទូរទស្សន៍មួយចំនួន ដែលទាំងនេះឆ្លុះបញ្ចាំងអោយឃើញកាន់តែច្បាស់ ពីតម្លាភាពការបោះឆ្នោតដោយមិនគ្រាន់តែមន្ត្រីរៀបចំការបោះឆ្នោត អ្នកសង្កេតការណ៍ក៏ដូចជាអ្នកតំណាងគណបក្សនយោបាយទេ ដែលត្រូវដឹង ប្រជាពលរដ្ឋក៏អាចដឹង មើលឃើញ

និង យល់ពីដំណើរការនៃការរៀបចំការបោះឆ្នោតរហូតដល់ការរាប់សន្លឹកឆ្នោត ។ ឯកសារនេះមានភាពងាយស្រួលជាងមើលសៀវភៅនិតិវិធីរបស់ គ.ជ.ប ។ ដោយឡែកក៏មានផលិតឯកសារបន្ថែម ទាក់ទងនឹងការបណ្តុះបណ្តាល និង លិខិតបទដ្ឋានឬក៏សេចក្តីណែនាំផ្សេងៗដើម្បីបំរើការងារបោះឆ្នោតនៅថ្ងៃបោះឆ្នោត ហើយក៏បានចែកផ្សាយទៅគណបក្សនយោបាយ និង អង្គការមិនមែនរដ្ឋាភិបាលខ្លះៗហើយ ។ **ទី៣** គឺការជ្រើសរើសមន្ត្រីការិយាល័យបោះឆ្នោតដែលជាបញ្ហាលំបាកមួយ ។ មកដល់ពេលនេះមិនទាន់មានរបាយការណ៏ច្បាស់លាស់ណាមួយ បញ្ជាក់ថាខ្វះមន្ត្រីការិយាល័យបោះឆ្នោត ។ លើកមុនមន្ត្រីការិយាល័យ បោះឆ្នោតមានចំនួន៥នាក់ ប្រធានការិយាល័យទទួលបានប្រាក់កំរៃ៥ដុល្លារក្នុងមួយថ្ងៃ អនុប្រធាន ៤ដុល្លា សមាជិក ៣ដុល្លារ ធ្វើការរយៈពេល៥ថ្ងៃ សំរាប់ការបោះឆ្នោតលើកនេះ ប្រាក់កំរៃផ្តល់អោយដដែល ប៉ុន្តែបន្ថែមមនុស្សម្នាក់ទៀត រយៈពេលធ្វើការកាត់មកនៅ រយៈពេល៣ថ្ងៃវិញ ហើយមន្ត្រីខេត្តក៏ដូចជាមន្ត្រីឃុំសង្កាត់រៀបចំការបោះឆ្នោត មានការព្រួយបារម្ភមិនមានប្រជាពលរដ្ឋមក ដាក់ពាក្យធ្វើការងារនេះ ។ ការដាក់ពាក្យសុំបំរើការងារនេះគឺផ្តល់ជូនតាំងពីថ្ងៃទី១៩ មកម្ល៉េះ ដោយសារមានការបារម្ភពីបញ្ហានេះ គ.ជ.ប បានបន្ថយអាយុអ្នកដែលចូលបំរើការងារនេះ ដែលពេលមុននៅក្នុងនិតិវិធីយកចាប់ពី អាយុ២២ឆ្នាំទៅ ហើយពីម្សិល មិញនេះ គ.ជ.ប បានចេញលិខិតណែនាំមួយទៀត គឺថាយកចាប់ពីអាយុ១៨ឆ្នាំឡើងទៅ ដែលអាចអោយនិស្សិត ឬ សិស្សអាចចូលបរើ ការងារនេះបាន។ ហើយមន្ត្រីទាំងអស់នេះមាន ៦៨ ៥៦៨នាក់ ដោយក្នុងមួយតំណាងមានបំរុង២ នាក់ទៀត ដូចនេះ ចំនួនអាចកើតឡើងដល់ ១៨០០០០នាក់ ក្នុងករណីមានការផ្លាស់ប្តូរ ហៅអ្នកបំរុងមក ធ្វើការណែនាំ ហើយអោយបំពេញការងារតែម្តង ដូចនេះហើយបានជាមានផលិត ឯកសារបន្ថែម និង ឈុតវីដេអូដែលអាចអោយគាត់មើលកន្លះម៉ោងហើយយល់ការងារបាន ។ មន្ត្រីដែលបានជ្រើសរើសហើយ គ.ជ.ប នឹងធ្វើការតែងតាំងនឹងទទួលការបណ្តុះបណ្តាលមុនពេលបោះឆ្នោត ២ថ្ងៃ ថ្ងៃទី២ គាត់ធ្វើរៀបចំការិយាល័យបោះឆ្នោត និង ថ្ងៃទី៣គឺ ថ្ងៃបោះឆ្នោតតែម្តង ។ **ទី៤** គឺអ្នកសង្កេតការជាតិ និង អន្តរជាតិ រហូតមកដល់ពេលនេះមានអង្គការមិនមែនរដ្ឋាភិបាល ចំនួន ២៤ដែលបានដាក់ភ្នាក់ងារអ្នកសង្កេតការណ៏ ដែលមានចំនួន ១៣២៣៥ នាក់ ហើយអ្នកសង្កេតការណ៏អន្តរជាតិ មាន១០អង្គការ និង ក្នុងនោះមានស្ថានទូតមួយចំនួនដែរ ដែលមានអ្នកសង្កេតការណ៏ ១៥៤នាក់ ហើយនៅសល់អង្គការ៣ទៀតដែលកំពុងតែពិនិត្យការស្នើរសុំ ។ **ទី៥** ការឃោសនាមានសភាពស្ងប់ស្ងាត់ជាងមុន ។ ការបោះឆ្នោតលើកមុន គជប មិនបានរៀបចំកម្មវិធី ជូនគណបក្សនយោបាយ ដើម្បីធ្វើការផ្សព្វផ្សាយពីគោលនយោបាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិទេ ប៉ុន្តែឆ្នាំនេះមានរៀបចំកម្មវិធី ដោយអោយរយៈពេល ខុសគ្នា ចំពោះគណបក្សដែលចុះបញ្ជីឈ្មោះបេក្ខជនចាប់ពី ១០០០ ឃុំ/សង្កាត់ឡើងលើ បានរយៈពេល ៦នាទី តិចជាង ១០០០ឃុំ/សង្កាត់ បានរយៈពេល៥នាទី ហើយដំណើរការនេះត្រូវបានចាក់ផ្សាយរៀងរាល់ថ្ងៃ។ UNDP ក៏បានសហការជាមួយនឹង ក្រសួងព័ត៌មានរៀបចំ និង ធ្វើការចាក់ផ្សាយនៅប្រព័ន្ធផ្សព្វផ្សាយរដ្ឋដែរ គឺជាកម្មវិធីសមធមិជាចំណុចថ្មីដែលមិនធ្លាប់មានពីមុនមក ។ កម្មវិធីនេះមិនមែនជាកម្មវិធីនយោបាយទេ គឺជាកម្មវិធីព័ត៌មានសុទ្ធសាធដែលផ្អែកទាំងស្រុងទៅលើ សកម្មភាពរបស់គណបក្ស នយោបាយ ហើយគណបក្សនយោបាយមួយចំនួនមិនធ្វើសកម្មភាពអ្វីសោះនោះក៏កម្មវិធីនេះ ពិបាកក្នុងការចាក់ផ្សាយដែរ ។ តាមរយៈការធ្វើការឃោសនាកន្លងមកនេះមានការកត់សំគាល់មានរូបភាពធំៗ គឺការហែរក្បួនដូចជានៅក្នុងទីក្រុងភ្នំពេញគណបក្សសម រង្ស៊ី មានហែរក្បួនយ៉ាងធំទូទាំងក្រុងតែម្តង គណបក្សប្រជាជនកម្ពុជាបានធ្វើការការហែរក្បួននៅតាមឃុំសង្កាត់និមួយៗ និង គណបក្ស ហ៊្វុនស៊ិនប៉ិចបានហែរក្បួនទៅតាមឃុំសង្កាត់មួយចំនួន ចំណែកឯនៅតាមខេត្តមានការប្រជុំធំៗរបស់គណបក្សប្រជាជនកម្ពុជាបន្ទាប់មកបានបំបែកកំលាំងទៅតាមឃុំសង្កាត់ឯគណបក្សដ៏ទៃទៀតធ្វើទៅតាមលទ្ធភាពរបស់ខ្លួនដោយធ្វើនៅតាមផ្ទះ រឺ ធ្វើការប្រជុំតូចៗ ដើម្បីផ្សព្វផ្សាយពីគោលនយោបាយរបស់ខ្លួន ។ មានបញ្ហាមួយចំនួនតាមការសង្កេតឃើញថាប្រព័ន្ធផ្សព្វផ្សាយ និង អ្នកសង្កេតការ មួយចំនួនលើកឡើងតែចំណុចអសកម្មរបស់គណបក្សមួយចំនួន ប៉ុន្តែមួយចំនួនទៀតមិនលើកឡើង ឧទាហរណ៏ដូចជាមានគណបក្ស មួយធ្វើការប្រជុំ ហើយគណបក្សមួយទៀតធ្វើ

ហែរកាត់នៅក្នុងភូមិ គណបក្សមួយទៀតទៅបិទមេក្រូ និង ដកមេក្រូមិនមានអ្នក និយាយអ្វីសោះ តែបើគណបក្សមួយទៅបិទមេក្រូ និង ដកមេក្រូពីគណបក្សមួយទៀតស្រែកឆោឡោភ្លាម ។ ឯកឧត្តម ស្នើអោយគ្រប់ស្ថាប័នដែលទាក់ទងនឹងបញ្ហានេះ សូមមើលអោយបានសងខាង ។ នៅក្នុងការឃោសនាបោះឆ្នោតប្រព័ន្ធផ្សព្វផ្សាយ របស់រដ្ឋមានលក្ខណៈល្អប្រសើរច្រើន ប៉ុន្តែប្រព័ន្ធផ្សព្វផ្សាយឯកជនមិនទាន់អាចគ្រប់គ្រងបានទេ ហើយ គជប បានទៅទាក់ទងទៅ នឹងក្រសួង ក៏ដូចជាទៅស្ថានីយ៏ផ្ទាល់ ហើយពេលសប្តាហ៏ខាងមុខនឹងធ្វើហៅពួកគាត់មកជជែកគ្នាម្តងទៀតព្រោះពួកគាត់នៅតែផ្សាយ លំអៀងម្ខាង។ ទោះបីជាលក្ខណៈព័តិមានក៏ដោយក៏មានលក្ខណៈលំអៀងទៅរកគណបក្សដែលឈរច្រើនឃុំ/សង្កាត់ ដោយឡែក គណបក្សមួយចំនួនតូច ដែលមានអ្នកឈរឈ្មោះនៅឃុំ/សង្កាត់តិចក៏មិនមានការផ្សព្វផ្សាយដែរ ។

លោក **ម៉ារ សុផល** មន្ត្រីសម្របសម្រួលផ្នែកអង្កេត ខុមហ្វ្រែល បានមានប្រសាសន៏ថានៅក្នុងដំណើរការការឃោសនាបោះឆ្នោតនៅឆ្នាំនេះ លោកបានទទួលស្គាល់ថាដំណើរការនៃការធ្វើឃោសនាការបោះឆ្នោតដែលប្រព្រឹត្តទៅកន្លងមកប៉ុន្មានថ្ងៃនេះដោយមានលក្ខណៈល្អប្រសើរ ហើយគណបក្សនយោបាយមានសភាពសកម្មក្នុងការធ្វើការការឃោសនា តាមការអង្កេតមិនទាន់មានឃើញមានអំពើហឹង្សារបង្ករបួសស្នាមគួរអោយតក់សំគាល់នៅឡើយទេ ហើយបញ្ហាឃាតកម្មក៏មិនទាន់ឃើញកើតគណបក្សទាំងអស់ ការប្រើពាក្យសំដីមានលក្ខណៈចាស់ទុំជាងមុនព្រមទាំងមានការអធ្យាស្រ័យគ្នាទៅវិញទៅមក ក្នុងនោះបញ្ហាដែលកើតឡើងគឺមានការសំរបសំរួលពីអាជ្ញាធរ និង ជាពិសេសមន្ត្រីរៀបចំការបោះឆ្នោត ។ ករណីការរាំងស្ទះ ឬ ការគំរាមកំហែងក្នុងដំណើរការការឃោសនាបោះឆ្នោតតាមរយៈ ពាក្យសំដីក្តី តាមរយៈកាយវិការក្តីបើរាប់ជាចំនួនករណីវិញ គឺមានការថយចុះជាងមុនច្រើន បើប្រៀបធៀបទៅនឹង ការឃោសនាបោះឆ្នោតនៅឆ្នាំ២០០២ ។ នៅក្នុងឆ្នាំ២០០២ គិតជាមធ្យមករណីការគំរាមកំហែង ការបង្កទំនាស់ពាក្យសំដី និង ការបង្ករបួសស្នាមកើតឡើងជាង ១០ករណី ក្នុង១ថ្ងៃ ហើយនៅក្នុងឆ្នាំនេះ ករណីនេះកើតឡើងជាមធ្យមតែ ៥ករណី ជាមធ្យមក្នុង១ថ្ងៃ ប៉ុន្តែយើងមិនទាន់ដឹងពីឥទ្ធិពលនៃការរារាំងនោះនៅឡើយទេ លោកក៏បានសំណូមពរផងដែរសូមអោយគណបក្សទាំងអស់បើអាចសូមអោយបញ្ឈប់តែម្តងដោយប្រកួតអោយមានភាពសេរី និង យុត្តិធម៌មានតម្លាទៅតាមគោលនយោបាយរបស់គណបក្សរបស់ខ្លួន ។ ចំណែកឯប្រព័ន្ធផ្សាយ លោកសូមឯកភាពជាមួយ ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គ.ជ.ប ពាក់ព័ន្ធទៅនឹងប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសរបស់រដ្ឋសង្កេតឃើញថាខិតខំរក្សាអព្យាក្រិតរបស់ខ្លួនបានច្រើនជាងអំឡុងពេលមុន១ ប៉ុន្តែនៅក្នុងនោះសង្កេតឃើញមានប្រព័ន្ធផ្សព្វផ្សាយមួយចំនួនរួមមានទូរទស្សន៍ វិទ្យុ និងសារព័តិមានបោះពុម្ពនៅតែមិនទាន់គោរពគោលការណ៏ ក្រមសីលធម៌ដែលចេញដោយ គ.ជ.ប និង ក្រសួងព័តិមាន ដោយសារប្រព័ន្ធផ្សព្វផ្សាយទាំងនោះនៅតែផ្សាយលំអៀងទៅលើគណបក្ស យ៉ាងខ្លាំងម្ខាង១ ជាពិសេសតាមការសង្កេតរបស់ខុមហ្វ្រែលដែលធ្វើកន្លងមកទៅប្រព័ន្ធផ្សព្វផ្សាយទាំងនោះគឺលំអៀងខ្លាំងទៅលើគណបក្សដែលបានដាក់បេក្ខជនលើ ១០០០ឃុំ ចំណែកគណបក្សដែលដាក់បេក្ខជនតិចជាង ១០០០ឃុំ មិនសូវឃើញបានទទួលការផ្សព្វផ្សាយទេ ។ ទាក់ទងនឹងបញ្ហានេះ ខុមហ្វ្រែលក៏បានជំរាបជូនជាព័តិមាន និង មានសំណើរទៅ គជប សូមអោយមានវិធានការដែលក្នុងនោះមានទូរទស្សន៍ វិទ្យុ និងសារព័តិមានបោះពុម្ពចំនួន ១៥ ដែលមាននិន្នាការលំអៀងខ្លាំង។ លោកក៏បានលើកឡើងពីសំដីឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គជប ដែលបានលើកឡើងថាសប្តាហ៏ក្រោយនឹងធ្វើការអញ្ជើញប្រព័ន្ធផ្សព្វផ្សាយទាំងនោះមកជជែកវែកញែកនោះ លោកយល់ថាហាក់ដូចជាយឺតពេលពេកហើយព្រោះការធ្វើការឃោសនាបោះឆ្នោតមានរយៈពេលខ្លី ដូចនេះលោកមានសំណូមពរថាបើអាចធ្វើទៅបានសូមអោយធ្វើនៅសប្តាហ៏នេះតែម្តងទៅ ព្រោះប្រព័ន្ធផ្សព្វផ្សាយបានដើរតួនាទីចំបងក្នុងការផ្តល់ព័តិមានដល់ប្រជាពលរដ្ឋ ។ ពាក់ព័ន្ធនឹងមិនប្រក្រតី លោកក៏បានទទួលដំណឹងមួយអំពីប្រធានគណកម្មាការឃុំរៀបចំការបោះឆ្នោតបានលើកផ្លាកសញ្ញាគណបក្សប្រជាជនកម្ពុជានៅផ្ទះរបស់គាត់ ករណីនេះកើតឡើងនៅឃុំពោរាជ ស្រុកស្វាយជ្រុំ ខេត្ត

ស្វាយរៀង ។ នេះជារឿងមួយមិនប្រក្រតីព្រោះគាត់ ប្រធានគណកម្មាការឃុំរៀបចំការបោះឆ្នោតត្រូវមានតួនាទីអព្យាក្រិត ។ សំរាប់ដំណើរការបោះឆ្នោតខាងមុខនេះ ខុមហ្វ្រែលបានដាក់អ្នកសង្កេតការណ៍ ១០០០០នាក់ ទូទាំង២៤ខេត្តក្រុង ក្នុងនោះដែរ ខុមហ្វ្រែលក៏បានធ្វើជាម្ចាស់ផ្ទះ ទទួលអ្នកសង្កេតការអន្តរជាតិ មកពីប្រទេសអ៊ីរ៉ាក់១២នាក់ អង្គការជប៉ុនដែលមានសមាជិកប្រហែលជា១២នាក់ ហើយក៏មានជនបរទេសដែលធ្វើការនៅប្រទេសកម្ពុជាផងដែរ ដែលចាប់អារម្មណ៍លើរឿងនេះ ។

លោក **សំ សុគន្ធារី** មន្ត្រីសម្របសម្រួល NICFEC បានមានប្រសាសន៍ថាទាក់ ទងទៅនឹងដំណើរការឃោសនាបោះឆ្នោត អ្នក អង្កេតការណ៍ NICFEC មាន ចំនួន១៥០នាក់ ដែលធ្វើការទៅលើ៧ខេត្តក្រុង ហើយយោងតាមរបាយការណ៍ដែលផ្តល់ដោយអ្នកអង្កេត ការណ៍១៥០នាក់នេះគឺក្នុងរយៈពេលឃោសនាបោះឆ្នោតរយៈពេល៥ថ្ងៃកន្លងមកមានភាពរលូនល្អប្រសើរបើប្រៀបធៀបទៅនឹងការឃោសនាបោះឆ្នោតកន្លងមក ។ លោកសង្កេតឃើញថាការរីកចំរើននេះគឺដោយសារតែគណបក្សនយោបាយជាកត្តាចំបងដែលបានណែនាំល្អនៅថ្នាក់មូលដ្ឋានបានល្អ ហើយនៅមានកើតឡើងនូវបញ្ហាមានតិចបំផុត NICFEC នឹងចេញសេចក្តីថ្លែងអំពីដំណើការឃោសនាបោះឆ្នោតដែលធ្វើឡើងរយៈពេល៥ ទៅ ៦ ថ្ងៃនេះនៅកំឡុងពេលពីរថ្ងៃខាងមុខនេះ ហើយ នឹងចេញមួយទៀតក្រោយពេលឃោសនាបោះឆ្នោត ។ NICFEC បានចេញសេចក្តីថ្លែងការណ៍រួមរបស់ NICFEC YCC YRDP ទាក់ទងនឹងការចែកប័ណ្ណលើកទី២ ដែលដំណើការនៃការចែក ប័ណ្ណក៏មានលក្ខណៈល្អប្រសើរដែរ។ មួយទៀតទាក់ទងទៅនឹងការអ្នកសង្កេតការណ៍រយៈពេលខ្លីមាន២ប្រភេទគឺ អ្នកអង្កេត ការណ៍ជាត និង អន្តរជាតិ ហើយ NICFEC មានគំរោងជ្រើសរើសអ្នកអង្កេតការណ៍៥០០០នាក់ ហើយឥលូវនេះ NICFEC ជ្រើសរើស បាន៤០០០នាក់ ក្នុងចំណោម៤០០០នាក់នឹងបណ្តុះបណ្តាលប្រហែលជាង២០០០នាក់ និង អ្នកសង្កេតការណ៍អន្តរជាតិដែលដាក់ ពាក្យធ្វើអ្នកសង្កេតការណ៍បានចំនួន៥០នាក់ ហើយ ។

លោក **ឱក សេរីសោភក្តិ៍** សូមអញ្ជើញគណបក្សដែលមានដាក់បេក្ខជនតិចជាង១០០០ឃុំលើកឡើងពីគំលាតរវាងគណបក្សធំៗ និង គណបក្សតូចៗ ។

ឯកឧត្តម **អ៊ុក ភូរិ** ប្រធានគណបក្សប្រជាធិបតេយ្យខ្មែរ KDP បានមានប្រសាសន៍ថ្លែងអំណរគុណចំពោះវិទ្យាស្ថាន CDRI ដែលបានផ្តល់ សេចក្តីសង្ឃឹមដល់គណបក្សតូចៗក្នុងនោះមានគណបក្សប្រជាធិបតេយ្យខ្មែរផងដែរ ។ ឯក ឧត្តមបានមានប្រសាសន៍គាំទ្រនូវការ រីកចំរើននូវ ដំណើការបោះឆ្នោតដែលចាប់ផ្តើមតាំងពីមិនទាន់មានច្បាប់ជាអាទិ ច្បាប់គណបក្សនយោបាយ ច្បាប់ការបោះឆ្នោតរហូត មកដល់ បច្ចុប្បន្នដែលមានច្បាប់គណបក្សនយោបាយ ច្បាប់បោះឆ្នោត និង និតិវិធីមួយចំនួនបានរៀបចំដោយ គជប បើទោះបីជា មានការ ខ្វះខាតមួយចំនួនដែលទាក់ទងទៅនឹងការវាយតំលៃអំពីភាពមិនប្រក្រតីក៏ដោយ ។ ឯកឧត្តម សូមបែរមកនិយាយពីការរៀបចំ គណបក្សមានបេក្ខជនតិចជាង ១០០០ឃុំហើយ ឯកឧត្តមមានការសោកស្តាយដោយសារតែនៅពេលដែលឯកឧត្តមបានចូលរួម បញ្ចេញមតិ ដោយសារឃើញគណបក្សខ្លះបាន ៦នាទី គណបក្សខ្លះបាន ៥នាទី ។ ឯកឧត្តមគិតថាមួយនាទីមានសារៈសំខាន់ណាស់ហេតុអ្វីបានជាអោយ គណបក្ស ធំហើយបាន ៦នាទី គួរតែអោយគណបក្សតូច តាមយោបល់របស់ឯកឧត្តមសូមអោយគណបក្សទាំងអស់បានម៉ោងស្មើគ្នា ។ ឯកឧត្តមមានសុទិដ្ឋិនិយមចំពោះស្ថានភាពបច្ចុប្បន្ន ដោយមានការរៀបចំរចនាសម្ព័ន្ធតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋានដើម្បីរើស អ្នកដឹកនាំដើម្បីបំរើប្រជាពលរដ្ឋ និង សូមអោយវិទ្យាស្ថាន CDRI នៅតែបន្តអង្គប្រជុំការប្រជុំនេះ ។

លោក **គីង ម៉ៅ** មកពីគណបក្ស សម រង្ស៊ី បានមានប្រសាសន៍ថាទាក់ទងទៅនឹងការឃោសនាបោះឆ្នោតនៅខេត្តបាត់ដំបងដែលនៅថ្ងៃទី១ លោក **ដួង សារុម** ដែលជាអធិការរងស្រុកបានគំរៀមដល់អ្នកលក់សាំងកុំអោយលក់សាំងអោយអ្នកហែរក្បួន ហើយឈ្មោះ **ឃើន** ខាងគណបក្សប្រជាជនកម្ពុជាបានដើរហែកខិតប័ណ្ណគណបក្ស សម រង្ស៊ី ហើយមានរឿងជាច្រើនទៀតដូចជានៅខាងកោះ

ក្រឡមានច្រើន ប៉ុន្តែលោកសូមលើកយកតែពីរករណីខាងលើ ។ មួយទៀតមាននៅខេត្តកំពតដែលមានការគំរាមកំហែងប្រជាពលរដ្ឋនៅភូមិចាក់ជ្រៃ ឃុំព្រែកដំបូក ដែលបានចូលរួមក្នុងការឃោសនាបោះឆ្នោតរបស់គណបក្ស សម រង្ស៊ី នឹងត្រូវដកប័ណ្ណបោះឆ្នោត ។ នៅកោះកុង ក្នុងឃុំព្រែកខ្សាច់ មានបីគណបក្សគាត់ចែក៩ថ្ងៃម្នាក់តែម្ដងក្នុងការឃោសនាបោះឆ្នោត បើគណបក្សណាដែលដើរខុសថ្ងៃដែលបានកំណត់គឺមិនបាន ។ នៅឃុំ ស្មាច់មានជ័យមេភូមិ គាត់ដើរប្រមូលប្រជាពលរដ្ឋទៅឃោសនា ប៉ុន្តែគាត់មិនមែនជាបេក្ខជនទេក្នុងលក្ខខណ្ឌបើគាត់ជាបេក្ខជន គាត់អាចធ្វើបាន ចំណែកខាងលោកបានទៅនិយាយប្រាប់គាត់ ប៉ុន្តែគាត់ថាមិនព្រម នៅពេលនោះខាងលោកបានប្រាប់គាត់ថាបើមិនព្រមប្ដឹងពេលនោះគាត់ក៏បានដកថយ ហើយយើងក៏អត់ប្ដឹងដែរព្រោះពេលខ្លះយើងអាចសំរួលគ្នាបាន ។ នៅ ខេត្តកោះកុង គឺនៅក្នុងឃុំត្រពាំង រូង មេភូមិទៅរៀបចំប្រជាពលរដ្ឋទៅបោះឆ្នោតតែម្ដង ដោយរៀបចំថាភូមិនេះត្រូវ អ្នកនេះហើយភូមិនោះត្រូវអ្នកផ្សេងទៀត គឺគាត់រៀបចំដូច្នេះមិនដឹងជានរណាប្រាប់គាត់ទេ ខាងលោកកំពុងតាមដាន ហើយក៏បានប្ដឹងទៅគ្រប់ស្ថាប័នអស់ហើយ ។ ចំណែកនៅឃុំ ភ្នីមាសនៅមានការគំរាមកំហែងនៅតែបន្តដដែល ដោយសារភ្នីមាស គ្មានសេវាទូរស័ព្ទ ។ មួយទៀតមានការបាញ់ផ្ទុះអាវុធនៅ ឃុំរស្មី ស្រុកក្រវ៉ាញចំនួន ៣ គ្រាប់នៅវេលាម៉ោង ១២ ចំនួន១គ្រាប់ ម៉ោង ២ ចំនួន១ គ្រាប់ និង ម៉ោង ៣ ចំនួន១គ្រាប់ដែលនាំឱ្យបំភ័យដល់សកម្មជនគណបក្សសម រង្ស៊ីដែលត្រូវហែរក្បួននៅថ្ងៃទី ១៩ ។ ថ្ងៃ ១៨ គាត់បាញ់ដើម្បីបំភ័យសំរាប់ថ្ងៃ ទី ១៩ ព្រោះ តំបន់ព្រៃវិហារការធ្វើ ដំណើរគឺពិបាកមែនទែន ដោយសារតែឆ្ងាយ ។ ចំណែកអ្នកបាញ់យើងកត់សំគាល់មិនទាន់បានទេបើដឹងឈ្មោះភ្លាម យើងដាក់ប្ដឹងភ្លាម ។ រីឯនៅខាងប៉ៃលិនមានវាយប្រតប់គ្នា ពេលគាត់មកពីឃោសនាគាត់ក៏ដើរមើលគេហើយបេក្ខជនគណបក្សប្រជាជន វាយគាត់តែម្ដង ។ ចំពោះការហែកខិតប័ណ្ណកើតឡើងសឹងតែទូទាំងប្រទេស ប៉ុន្តែកើតឡើង ច្រើនជាងគេនៅកំពង់ចាម និងបាត់ដំបង ដែលខិតប័ណ្ណ គណបក្សសមរង្ស៊ី បិទហើយ ហែក ហើយខាងលោកក៏មានក្រុម សំរាប់ឃ្លាំ មើលផងដែរប៉ុន្តែ មិនដែលជួបអ្នកហែកសោះ ។ នៅកំពង់ធំ ឃុំមានរិទ្ធិ ស្រុកសណ្ដាន់ មានចាក់មេក្រូរបស់គណបក្សប្រជាជនហើយ ស្រែកមកលើផ្លាករបស់គណបក្សលោក ហើយថាពួកគេ កុំតែបាន ៧ មករា ហើយគាត់ជេរគណបក្ស សមរង្ស៊ី ។ ហើយលោកសូម សំណូមពរឱ្យខាង គជប សូមជួយអន្តរាគមន៍ ព្រោះកន្លងមកពេលយើង ប្ដឹងខាងប៉ូលីសតែងតែ និយាយថា សូមរកស្តុតាងដោយលោក យល់ថាគាត់ជាប៉ូលីស គាត់ត្រូវតែ ទៅរកភស្តុតាងពេលគេនិយាយ តែ គាត់នៅតែនិយាយថាតំរូវភស្តុតាងពីខាងយើង។

កញ្ញា **ហេង ចន្ទី** មកពីអង្គការជនពិការកម្ពុជា ចំពោះការឃោសនាបោះឆ្នោត កញ្ញាផ្ទាល់ បានប្រទះនូវបញ្ហាមួយចំនួនទាក់ទងនិងការបិទប្រកាសការឃោសនា មានគណបក្សមួយចំនួនបានបិទក្រដាសឃោសនានៅតាមផ្ទះប្រជាជន និមួយៗ ធ្វើឱ្យមានការភាន់ច្រលំ និងឈ្លោះប្រកែកគ្នាជាពាក្យសំដី ខ្លះដែរ ចំពោះនៅតាមភូមិឃុំ មួយចំនួនក៏ដូច្នោះដែរគឺមានការប្រកាន់បក្សពួក ដូច្នេះការឃោសនា ការបោះឆ្នោតហើយនិង ការផ្សព្វផ្សាយជាក្រដាសបិទនៅតាមផ្ទះ គឺគាត់បិទមិនគ្រប់ផ្ទះទេដែលនាំឱ្យមានការប្រឆាំងគ្នាដូច្នេះហើយកញ្ញាចង់ឱ្យខាង គជប ក៏ដូចជាគណបក្សតំណាងផ្សេងៗ ជួយធ្វើការពិចារណាចំពោះរឿងឃោសនានេះផងដែរ ។

លោក **អ៊ុក គឹមហាន** មកពី គណបក្សប្រជាជនកម្ពុជា សូមពាំនាំ នូវព័ត៌មានមួយចំនួនដើម្បីជំរាបជូនអង្គប្រជុំ និងធ្វើការវិភាគទាំងអស់គ្នា ដោយលោកគិតថា ការវាយប្រតប់គ្នាជារឿងធម្មតាទេ ដោយមិនមែនតែគណបក្សប្រជាជនរំលោភលើគណបក្សដ៏ទៃទៀតទេ ហើយក៏មានគណបក្សដ៏ទៃទៀតក៏រំលោភមកលើគណបក្សប្រជាជនដែរ។ នៅថ្ងៃទី ១៦ នៅខេត្តកំពុងស្ពឺក៏មានបញ្ហាវាយប្រតប់ហ្នឹងកើតឡើងដែរ នៅពេលដែលគណបក្សប្រជាជនមានជំទប់ទី ១ របស់ គណបក្សមួយនោះទៅបិទមេក្រូ របស់ក្បួនហែររបស់គណបក្សប្រជាជន នៅពេលនោះក៏មានការប្ដឹងផ្ដល់គ្នាទៅដល់ CEC ហើយគណកម្មាការឃុំ-សង្កាត់រៀបចំការបោះឆ្នោតក៏បានធ្វើការសំរបសំរួល គឺគាត់ដើរតួនាទីខ្លាំងណាស់នៅពេលហ្នឹង ។ នៅមានកន្លែងខ្លះទៀតចាក់មេក្រដោយសារស្នាក់ការគណបក្សនៅជិតគ្នា ចាក់មេក្រូប្រឆាំងគ្នាទៅវិញទៅមក ឱ្យ CEC ទៅសំរបសំរួលដោយឱ្យបែរទៅម្ខាងម្នាក់ មិនព្រមវៀងខ្លួន ។ បញ្ហា

មួយទៀតនៅកំពង់ឆ្នាំង ក្នុងរបាយការណ៍ដែលលោកទទួលបានគណបក្សប្រជាជនបានប្តឹងទៅ ដោយមានគណបក្សផ្សេងមកបិទមេក្រូម្តងជាពីរដងនៅពេលឃោសនា រួចក៏ប្តឹងទៅ CEC ពេល CEC សំរបសំរួលដល់គណបក្សប្រជាជនមិនព្រម ហើយពេល នោះគាត់ក៏បានសារភាពថាគាត់ទៅបិទមេក្រូជាការខុសឆ្គងមួយ ហើយដូច្នេះការសំរបសំរួលក៏ចប់ត្រឹមហ្នឹងដែរ។ ចំណែកនៅប៉ោយប៉ែត ថ្ងៃទី ១៦ នៅពេលដែលគណបក្សប្រជាជនហែរក្បួន ជាទ្រង់ទ្រាយធំ ក្រោយមកក៏មានគណបក្សមួយទៀតក៏បានហែរដែរ នៅ ពេលហែរពីក្រោយដោយមិនបានឃោសនាអំពីគោលនយោបាយរបស់ខ្លួនទេ ប៉ុន្តែវាយប្រហារនិងជេរគណបក្សប្រជាជននេះក៏ជា បញ្ហាមួយដែលផ្ទុយនឹងនិតិវិធីដែរ ។ លោកជំរាបជូនអង្គប្រជុំថាចំពោះបញ្ហាវាយប្រតប់ និងជេរគ្នា គឺកើតឡើងជាធម្មតាទេ ហើយ លោកចង់ជំរាបជូនថា ទិដ្ឋភាពនៃការឃោសនាលើកនេះគឺមានលក្ខណៈប្រសើរជាងលើកមុន។

លោក **ឡឿ សុខុម** មកពីសម្ព័ន្ធប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា សូមលើកអំពីបញ្ហាជុំវិញការឃោសនាបន្តិច ហើយរឿងនេះ គឺកើតឡើងចំពោះកម្មករ មុនពេលឃោសនាបោះឆ្នោតទៀតដោយកន្លងមកលោកសង្កេតឃើញ នៅតាមរោងចក្រភាគច្រើនមានខាងថ្នាក់ដឹកនាំសហជីព ហើយជាទូទៅគេឱ្យនាមសហជីពមាន ៣ ដែលសហជីពរបស់ រាជរដ្ឋាភិបាល សហជីពរបស់ ថៅកែ និងសហជីពរបស់កម្មករ ។ លោកឃើញសហជីពមួយ តែមិនដឹងថាសហជីពរបស់ កម្មករ ឬរាជរដ្ឋាភិបាលទេ គាត់ទិញទឹក ចិត្តកម្មករមានកត់ឈ្មោះ កត់អត្តលេខ ផ្តិតមេដៃ ដោយឱ្យជាសារុង កន្សែង និងប្រាក់ ១ ម៉ឺនរៀល។ ទាក់ទងនឹងថ្នាក់ដឹកនាំ សហជីព ដូចខាងលោក គឺរងនូវការគំរាមគំហែងដោយ គាត់មិនព្រមផ្តិតមេដៃ និងមិនព្រម ទទួលយកលុយ ១ម៉ឺនរៀល គាត់មានការភ័យខ្លាចថាថៅកែនឹងបញ្ឈប់គាត់ពីការងារ ហើយជាទូទៅលោកសង្កេតឃើញថាថៅកែដូចជាផ្តល់ឱកាសដល់ជនទាំងនោះមកគំរាមគំហែង កម្មករហើយភាគច្រើនសមាជិកដូចពួកលោកត្រូវបានលាលែង ដោយគាត់គិត ថាបើគាត់នៅតែបន្តគាំទ្រខាងលោក ថៅកែនឹងបញ្ឈប់ការងារ។ ទាក់ទងនឹងការឱ្យឈប់សំរាកបោះឆ្នោតដែលប្រកាសខាងក្រសួងការងារចេញ សំរាប់នៅទីក្រុងភ្នំពេញគឺឱ្យឈប់ មួយថ្ងៃ គឺត្រូវនឹងថ្ងៃ អាទិត្យដដែលបើគាត់មិនចេញឱ្យឈប់ក៏បុគ្គលិកនៅតែឈប់ដដែលដោយសារថ្ងៃបោះឆ្នោតជាថ្ងៃអាទិត្យ។ ហើយ ចំណែកឯសំរាប់ អ្នកនៅតាមខេត្តចំនួន ៣ គឺ កណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង ឱ្យឈប់ ២ថ្ងៃគឺ ថ្ងៃ ទី ៣១ និង ទី ១ ក្រៅពីនេះលោកឃើញថាដូចជាប៉ះពាល់ដល់កម្មករខ្លាំងដូចជានៅកំពង់ឆ្នាំង ការបោះឆ្នោត ចប់ប្រហែលជា ម៉ោង ៣ ជូនកាលគាត់មិនអាចមកវិញទាន់ បើសិនជាគាត់បង្ខំថាមកចូលធ្វើការគាត់ត្រូវមកទាំងយប់នាំឱ្យប៉ះពាល់ដល់ សុវត្ថិភាពពេលធ្វើដំណើរផងដែរ ហើយលោកគិតថាដូចជា ពេលខ្លីបន្តិចសំរាប់ពួកគាត់ ខេត្តឯទៀតអាចឈប់សំរាកបាន ៣ថ្ងៃគឺ ថ្ងៃទី ៣១ ១ និងទី ២។ លោកគិតថាដូចជាខ្លីពេកសំរាប់ពួកគាត់ នេះក៏ជាសំណូមពររបស់កម្មករ ។ ចំនុចមួយទៀតគឺគាត់មិនមានលុយទេនៅពេលដែលគាត់ទៅ បោះឆ្នោត លោកគិតថាទោះជាមានសេចក្តីរបស់ក្រសួងថាឱ្យក្រុមត្រូវតែសំរួលបើកប្រាក់ខែឱ្យកម្មករមុន ថ្ងៃបោះឆ្នោតឬឱ្យខ្ចីមុន លោក គិតថាក្រុមហ៊ុនទាំងអស់មិនអាចអនុវត្តបានទាំងអស់ទេ ព្រោះជាទូទៅក្រុមហ៊ុនត្រូវការបិទបញ្ជីនៅថ្ងៃ ៣១ រាល់ខែ ក្រុមហ៊ុនតែងតែបើកប្រាក់ខែឱ្យកម្មករចន្លោះ ថ្ងៃ ៧ ដល់ថ្ងៃ ១៤ ។ ចំពោះការឱ្យខ្ចីក៏មានការពិបាកដែរ។ ដូច្នេះកម្មករ ភាគច្រើនគឺ អត់បានទៅបោះឆ្នោតដោយសារគ្មានលុយ ។ កម្មករមានការភ័យខ្លាចដែរដោយសារ មានការគំរាមពី ថៅកែ ឬ គណបក្សនយោបាយព្រោះបើកម្មករមិនទៅបោះឆ្នោតហើយគេអនុញ្ញាតិច្បាប់ឱ្យសំរាក ពេលនោះក្រុមហ៊ុន នឹងកាត់ប្រាក់ឈ្នួលប្រចាំថ្ងៃ និងប្រាក់រង្វាន់ប្រចាំខែ ដោយគាត់យល់ថាបើកម្មករណាមិនបានទៅបោះឆ្នោតគឺគាត់គ្មានស្នាមដៃ ខ្មៅទេ ហើយពេលធ្វើការគេសង្កេតមើលម្រាមដៃ ។ លោកសូមសំណូមឱ្យខាងគជប អង្គការ ក្រសួង និងស្ថាប័ន ដែលពាក់ព័ន្ធ និងការងារនេះសូមជួយសំរួលឱ្យកម្មករមានលក្ខណៈ សមរម្យជាងនេះ តាំងពីការបើកប្រាក់ខែ ការខ្ចីលុយមុន និង សូមឱ្យខាង គជប ជួយសំរួលឱ្យគាត់បោះឱ្យបានឆាប់បន្តិច ព្រោះគាត់ត្រូវមកធ្វើការវិញ ។

ឯក ឧត្តម **អ៊ុក ភូរិ** សូមបន្ថែម អំពីរឿងឈប់សំរាក ដោយសារ ឯកឧត្តមមានទំនាក់ទំនងខាងសមាជិក ឃើញថាកម្មករតាមរោងចក្រ បានទទួលប្រាក់តែពី ចន្លោះ ៦០$ ទៅ១០០$ កាលណាក្រុមហ៊ុនមិនបើកប្រាក់ខែ គឺកម្មករមិនទៅបោះឆ្នោតទេ ទោះបីជាឱ្យ ពេលសំរាកក៏ដោយ ក៏ត្រូវការប្រាក់ដើម្បីធ្វើដំណើរដែរ។ ទាក់ទងនឹងចែកខិតប័ណ្ណតាមទី ប្រជុំជន គណបក្សនយោបាយឥឡូវគឺមិនត្រូវបាន អនុញ្ញាតឱ្យចូលចែកខិតប័ណ្ណតាមប្រជុំជនឡើយ តើគណបក្សនយោបាយត្រូវចែកខិតប័ណ្ណនៅកន្លែងណា? ឯក ឧត្តម ស្នើឱ្យសំរួលដល់គណបក្ស ណាដែលគ្មានមធ្យោបាយព្រោះធ្វើគណបក្សនិមួយៗចង់ឱ្យគេដឹងពី គណបក្សរបស់ខ្លួន ហើយយើងធ្វើខិតប័ណ្ណមកគឺ មិនមែនចង់ ចែកឱ្យតែសមាជិករបស់ខ្លួនទេ គឺយើងចែកដល់ប្រជាពលរដ្ឋទាំងអស់ដើម្បីឱ្យមើលថាតើគណបក្សនេះ មានកម្មវិធីមាន គោលការណ៍ជាអាទិភាពអ្វី បើសិនជាគេមិនអនុញ្ញាតឱ្យចូលផ្សារតើចែកយ៉ាងដូចម្តេច? មិនត្រឹមតែប៉ុណ្ណោះបើចូលផ្សារ ចែករួចបន្តិចត្រូវបានប៉ូលីសផ្សារយកអស់ ។

ឯកឧត្តម **ទេព នីថា** បានបកស្រាយចំពោះបញ្ហាមួយចំនួនដូចខាងក្រោមនេះ ។ ទី១ យោបល់ខាង ខុមហ្វ្រែល ទាក់ទងទៅនឹងប្រពន្ធ័ ផ្សព្វផ្សាយឯកជន នឹងលើកទៅធ្វើនៅសប្តាហ៏ក្រោយដោយ នៅសប្តាហ៏នេះ គ.ជ.ប បានធ្វើការ ដោយផ្ទាល់ ជាមួយប្រព័ន្ធទាំងអស់នោះមួយចំនួនហើយ គឺមិនមែនធ្វើជារួមទេគឺយើងធ្វើដោយឡែក២ពីគ្នា ទាក់ទងនឹងប្រព័ន្ធដែល បានធ្វើការលំអៀង ។ និងនៅថ្ងៃស្អែកគ.ជ.បធ្វើសន្និសិទ្ធិនៅ គ.ជ.ប ប្រកាសថែមទៀតពីគោលបំណង គ.ជ.ប ជាមួយប្រព័ន្ធទាំងអស់នោះ។ នៅសប្តាហ៏ក្រោយ គ.ជ.ប នឹងហៅប្រព័ន្ធទាំងអស់ដែល ពាក់ព័ន្ធនឹងការផ្សាយលំអៀងមកប្រជុំគ្នាដើម្បីធ្វើការតែម្តង ។ ការដោះស្រាយការងាររបស់ គ.ជ.ប មានលំដាប់លំដោយព្រោះថាយើងមិនអាចហៅប្រមូលមកទាំងអស់នោះទេ ចំពោះបញ្ហានេះ យើងធ្លាប់មានការលំបាកហើយ ព្រោះបើហាមប្រព័ន្ធមួយបាន ប្រព័ន្ធមួយទៀតមិនព្រមឈប់ទេដោយសារតែមួយថាបើមួយបិទសិនទើបឈប់ ។ បញ្ហាមួយទៀតថានៅ ស្វាយរៀងមានមន្ត្រី គណកម្មាការឃុំលើកផ្លាក គណបក្សនយោបាយ គ.ជ.ប នឹងស្រាវជ្រាវឡើងវិញ ចំពោះបញ្ហានេះនៅនិតិវិធី មិនបាននិយាយទេ ឧទាហរណ៍ ផ្ទះជា របស់ឪពុកម្តាយគាត់ទេ តែលើកផ្លាកគណបក្ស ហើយ គាត់មកធ្វើការបោះឆ្នោតដូច្នេះ គ.ជ.ប មិនអាចដកផ្លាកចោលទេ ហើយបើសិនជាគាត់ជួលឱ្យគេលើកផ្លាកនេះជាអាជីវកម្មគាត់ ហើយគ.ជ.ប មិនអាច ដកគាត់បានទេ។ ចំពោះឯកសារបោះឆ្នោតមួយចំនួន គ.ជ.ប មិនបានបកប្រែទេ មួយចំនួនបានពី UNDP ដែលបានបកប្រែ ហើយ ឯកសារណាមាន គ.ជ.ប នឹងដាក់នៅក្នុង វិបសាយ ដែលអាចបើកបានប្រើប្រាស់ទាំងអស់គ្នា ។ ចំពោះ យោបល់ទី ២ ដែលខាង និចហ្វិច បានលើកឡើង ហើយឯក ឧត្តមសូមថ្លែងអំណរគុណដែលខាង និចហ្វិច បានសហការណ៍ ជាមួយ គ.ជ.ប ចំពោះការចែកប័ណ្ណព័តិមានទទួលបានលទ្ធផល ល្អ ទោះបីចែកបាន ៨១ % នៅសល់មនុស្សជាង ១ លាននាក់ក៏ ដោយ យើងក៏បានដឹងដែរថាបញ្ជីបោះឆ្នោតមានអ្នកខ្លះឈ្មោះស្ទួន និងភាគច្រើន ប្រជាពលរដ្ឋមួយចំនួនក៏ មិនបាននៅក្នុង ឃុំសង្កាត់ របស់ខ្លួនដែរ ។ ចំពោះបញ្ហាខុសឈ្មោះ ឯកឧត្តមទទួលស្គាល់ថាមានច្រើន ករណី ហើយ គ.ជ.ប ក៏បានធ្វើការណែនាំ ទៅមន្ត្រីរៀបចំការបោះឆ្នោតដើម្បីពិនិត្យ ជាក់ស្តែងដូចជាឈ្មោះផានឆាន ដោយសារតែ អក្សរ **ផ** និង **ជ** សរសេរដៃមកដូចគ្នា អ្នកមកបញ្ចូល ទិន្នន័យនៅ គ.ជ.ប វាយឈ្មោះគាត់ថា ជាន តាមពិតឈ្មោះគាត់ ផានទេ ។ ដូច្នេះម្ចាស់ឈ្មោះរក មិនឃើញទេ ហើយលោកក៏បាន វិលឹកទៅការិយាល័យបោះឆ្នោត ថាឱ្យពិនិត្យមើលនាមត្រកូល បើមិនឃើញ គឺមើលឈ្មោះខាងចុង បន្ទាប់មកទើបមើលទិន្នន័យ ផ្សេងទៀត ។ ចំពោះការណីនេះគឺ មិនច្រើនទេ។ បញ្ហា ដែលឯកឧត្តម អ៊ុក ភូរិបានលើកឡើង ចំពោះ បញ្ហាផ្សព្វផ្សាយ ដែល គ.ជ.ប ឱ្យ គណបក្សឈរឈ្មោះលើសពី ១៣ាន់ ៦ នាទី តិចជាង ១៣ាន់ ៥ នាទីនោះ គឺថាដោយពិនិត្យទៅលើ មូលដ្ឋានច្បាប់ ព្រោះច្បាប់ បោះឆ្នោត ឃុំសង្កាត់មិនបាននិយាយអំពីកម្មវិធីស្មើភាពទេ ហើយក៏មិនបានកំណត់ថាគណបក្សនយោបាយត្រូវឈរឈ្មោះឱ្យបាន ប៉ុន្មានភាគរយ នៃចំនួនអសនៈ ឬចំនួនមណ្ឌលទេ បើច្បាប់បោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រឱ្យមានកម្មវិធីស្មើភាព ដោយតំរូវឱ្យអ្នកដាក់ ពាក្យសុំ ឈរឈ្មោះត្រូវមាន ៣០ % ហើយត្រូវបង់

លុយទៀត ដូច្នេះករណីផ្សេងគ្នា បើថាករណីស្មើភាព មើលទៅឃើញស្មើ ទាំងអស់ ក្នុងករណីលទ្ធភាព និងអ្នកគាំទ្រ ដោយផ្អែកទៅលើរូបមន្តមួយចំនួនដែលគេប្រើ មានគណបក្សខ្លះឈរឈ្មោះតែមួយឃុំសង្កាត់គត់ រួចគណបក្សដាក់ច្រើនជាងគេគឺ ១៦២១ ឃុំ ហើយបើស្មើគ្នាទៅ ទី ១ យុត្តិធមិស្មើត្រឹមមែន ក៏ប៉ុន្តែអយុត្តិធមិ សំរាប់អ្នកដែលមានលទ្ធភាពច្រើន ហើយបើយើងថារូបមន្តបញ្ច្រាស់មកវិញថាឱ្យអ្នកឈរឈ្មោះតិច មានពេលវេលាច្រើនវិញ លោក គិតថាគ្រាន់តែរកឱ្យឃើញដើម្បីផ្តល់អាទិភាព ដល់អ្នកតិច ប៉ុន្តែរូបមន្តបោះឆ្នោតមិនអនុវត្តដូច្នោះទេសំរាប់ការផ្សព្វផ្សាយ ។ បញ្ហា រូបថត បើសិនជា គ.ជ.ប ប្រកាសពីដើទីថាខ្វះរូបថតអនុគ្រោះបានគឺ ខ្វះស្ទើតែគ្រប់កន្លែង ដូច្នេះបញ្ហាធំគឺតំរូវឱ្យមានរូបថត ហើយ អនុញ្ញាតឱ្យខ្វះរូបថតគឺយើងមើលឃើញថា ពេលមួយខ្វះ ហើយ កែតំរូវដើម្បីបំពេញការងារហ្នឹង ព្រោះបើប្រកាសពីដើមទីថាខ្វះបាន គឺខុសនឹង និតិវិធីរដ្ឋបាល ហើយ គ.ជ.ប កែតំរូវថាខ្វះបាន ដោយសារដើម្បីកែតំរូវនឹងសភាពការណ៍ជាក់ស្តែង ប៉ុន្តែចំពោះការខ្វះមិនមែន ឱ្យខ្វះរហូតទេគឺឱ្យបំពេញឡើងវិញ បញ្ហានេះទាក់ទងនឹងបច្ចេកទេសមួយហើយក៏ទាក់ទងនិងតំរូវការដែលយើងត្រូវឱ្យមានឯកសារ គ្រប់គ្រាន់សំរាប់ បំរើការបោះឆ្នោត ។ រីឯបញ្ហា លោក ម៉ៅ ខាងគណបក្ស សម រង្ស៊ី ចំពោះការចែកគ្នា ៥ថ្ងៃម្នាក់ជាការមិនត្រឹមត្រូវទេ ក៏ប៉ុន្តែលោកបានរំលឹកលើកមុនម្តងហើយ ខាងលោកក៏ណែនាំដែរ តែកន្លែងខ្លះ គណបក្សឯកភាពជាមួយគណកម្មាឃុំ-សង្កាត់តែម្តង ព្រោះយើងផ្តល់អាទិភាព ឱ្យគេសំរបសំរួលការងារចំណែកការអនុវត្តនៅខាងក្រោម គឺថាគណបក្សជូនព័តិមានមកថាធ្វើសកម្មភាព នៅ កន្លែងណា ឧទាហរណ៍ថា កន្លែងមួយសំរាប់គណបក្សមួយ ៥ថ្ងៃ ហើយកន្លែងផ្សេងទៀតគេដូរគ្នាអញ្ចឹងដែរ។ នេះជា ការផ្តល់ឱកាសឱ្យគេរៀបចំតាមការស្ម័គ្រចិត្ត នៅទីនោះតែបើចែកគ្នាឃោសនា ដោយ ១ គណបក្ស ធ្វើការឃោសនា ៥ ថ្ងៃ ហើយ ១០ថ្ងៃទៀតសំរាក គឺមិនត្រឹមត្រូវទេ គ.ជ.ប នឹងពិនិត្យបញ្ហានេះឡើងវិញ ព្រោះថាគ.ជ.បប្រយ័ត្នណាស់មុន នឹងគណបក្ស សំរបសំរួល កម្មវិធីឃោសនាជាមួយគណកម្មាការរៀបចំការបោះឆ្នោតឃុំ-សង្កាត់ សូមឱ្យមានកំណត់ហេតុ និងចុះហត្ថលេខាជាមួយគ្នាទាំងអស់ ដើម្បីចៀសវាងថាមានការគាបសង្កត់ ឬ វិតត្បិតពេលវេលា ។ ចំពោះបញ្ហាមួយទៀតដែលថាមានការបាញ់គំរាម បើសិនជាមាន ភស្តុតាង សូមជូនព័តិមានច្បាស់លាស់ ។ ករណីខ្លះគួរភ្ជាប់និងករណីខ្លះមិនគួរភ្ជាប់ទេ ជាក់ស្តែងដូចជាបាញ់ថ្ងៃ ១៨ ហើយហែរ ឃោសនាថ្ងៃ ១៩ ភ្ជាប់ទៅនឹងការគំរាមគំហែងដែរ ។ ឯក ឧត្តម សំណូមពរឱ្យមើលឱ្យបានច្បាស់ ព្រោះបើមិនដូច្នោះនឹង មើលឃើញ បរិយាកាសមួយស្មុកស្មាញពេក ។ ករណីដែលទាមទារឱ្យមានភស្តុតាងព្រោះជាការងារបោះឆ្នោតដោយមិនមានពេលវេលាទៅរក ភស្តុតាងទេ បើប្តឹងមកគណកម្មាការបោះឆ្នោតគឺគាត់មានពេលតែប៉ុន្មានថ្ងៃទេដើម្បីដោះស្រាយបញ្ហាហ្នឹង ហើយបើប្តឹងទៅ ប៉ូលិស គឺគាត់មិនបានកំណត់ពេលវេលាក្នុងការស្រាវជ្រាវទេ ហើយមិនត្រូវនឹងនិតិវិធីក្នុងការដោះស្រាយពាក្យបណ្តឹងរបស់គណកម្មាការរៀបចំការបោះឆ្នោត ។ ដូច្នេះការងារសំរាប់គណកម្មាការបោះឆ្នោតទាមទារឱ្យមានភស្តុតាង ឯកសារ ឬ សាក្សី ដើម្បីឱ្យងាយស្រួលនឹង ស្រាវជ្រាវ និងដោះស្រាយដោយសារតែការដោះស្រាយរបស់យើងត្រូវមានពេលវេលាកំណត់ច្បាស់ ។ ចំពោះសំនួរតំណាងអង្គការ ជនពិការ ឯកឧត្តមគិតថាការបិទប្រកាសលើផ្ទះប្រជាពលរដ្ឋ កន្លែងខ្លះក៏គេយល់ព្រមបិទកន្លែងខ្លះ ក៏គេបក់ចេញវិញ វាតាមលទ្ធភាព របស់គណបក្ស ហើយក៏តាមការផ្តល់ឱកាសរបស់គណបក្សដែរ ។ មានករណីដែលគណបក្ស ហែរហើយមកបិទតាមផ្ទះ តែក្រោយមកម្ចាស់ផ្ទះបកចេញ ។ មានករណីមួយទៀតនៅខេត្តកណ្តាល គណបក្សមួយហែរ បិទគ្រប់ផ្ទះ បន្ទាប់មកគណបក្សមក ក្រោយ បិទពីលើឬបក គណបក្សនោះចេញ ហើយបិទសារជាថ្មីទៀត ។ គណបក្សខ្លះទៀតក៏អត់បានបកខ្លួន ឯងទេ គឺមានក្រុមជើងល្អ ដើរបក ក្រុមហ្នឹងគឺជាបងធំនៅតាមភូមិឃុំ គាត់ដើរបកដោយគ្មាននរណាណែនាំ ឬជួលគាត់ទេ អាជ្ញាធរចាប់បាន ក៏មកសួរនាំរួចក៏ដោះស្រាយបានមួយរយៈ តែយប់ឡើងបន្តបកទៀត ។ ចំពោះករណីដូចខាងលើគណបក្សត្រូវជួបប្រជុំជាមួយ គណកម្មាការឃុំសង្កាត់រៀបចំការបោះឆ្នោតថា ត្រូវដោះស្រាយយ៉ាងដូចម្តេច ហើយ គ.ជ.ប ក៏បានបន្ថែមត្រង់ចំណុចហ្នឹងថាសូមសហការជាមួយអាជ្ញាធរដើម្បីការពារ ជាធម្មតាយើងមិនអាចការពារមួយកន្លែង មួយកន្លែងបានទេ

ព្រោះថាខាងតំណាងសន្តិសុខមានកំលាំងនៅមានកិរិតរបស់គាត់ ហើយការការពារគឺការពារជាប្រយោលក្នុងរូបភាពទ្រង់ទ្រាយរួមតែម្តង។ ចំពោះខាងសហជីពលើកឡើង ករណីទី ១ ដែលនិយាយអំពីការផ្តល់ថវិការ ជាការទាក់ទងនឹងការបោះឆ្នោត ហើយក៏ទាក់ទងនឹងការអូសកំលាំងទាញនៅក្នុងសហជីពដែរ ។ ចំពោះការឈប់សំរាក គ.ជ.ប គ្រាន់តែស្នើទៅក្រសួងមានសមត្ថកិច្ច ការផ្តល់ឱកាសរបៀបយ៉ាងម៉េចជាអន្តរគមន៏របស់ក្រសួងមាន សមត្ថកិច្ច ហើយថាខេត្តកំពង់ឆ្នាំងមកមិនទាន់ ឯកឧត្តមក៏យល់ដែរក៏ប៉ុន្តែការបោះឆ្នោតចប់នៅម៉ោង ៣ គាត់ទៅមុនមួយថ្ងៃ ហើយស្អែកឡើង គាត់អាចងើបទៅបោះឆ្នោតពីព្រលឹមទៅ បន្ទាប់មកនៅថ្ងៃត្រង់ គាត់អាចមកភ្នំពេញទាន់ហើយ ចំពោះអ្នកនៅ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ចំពោះការឱ្យឈប់សំរាកច្រើនទាក់ទងនិងការបោះឆ្នោតក៏ប៉ះពាល់ដល់ការងាររបស់រោងចក្រ ដែលជាការងារសេដ្ឋកិច្ចដែរ ។ ចំពោះអន្តរាគមន៏ទាក់ទងនឹងថវិការនេះ ខាងលោកនឹងរំលឹកក្រៅផ្លូវការទៅក្រសួង ដើម្បីអន្តរាគមន៏ថែមទៀត ព្រោះថាអ្វីដែលក្រសួងបានធ្វើជាទ្រង់ទ្រាយអន្តរាគមន៏ដែល គាត់បានធ្វើហើយ ប៉ុន្តែការអនុវត្តជាក់ស្តែងយ៉ាងណានោះ យើងមិនទាន់ដឹងទេរហូតដល់ថ្ងៃនេះ ដូចឯកឧត្តម **អ៊ុក ភូរិ** បានមានប្រសាសន៏ថាប្រហែលជាគេមិនបើកប្រាក់ខែឱ្យមុន ទៅតាមអន្តរាគមន៏របស់ក្រសួងទេ ហើយ គ.ជ.ប នឹងស្នើទៅខាងក្រសួងថែមទៀត ដើម្បីឱ្យគាត់ជួយរំលឹកបញ្ហានេះ ។ ចំពោះការគំរាមមិនបោះឆ្នោតកាត់លុយជាការមិនត្រឹមត្រូវ បើសិនជាខាងសហជីពមានព័ត៌មានគ្រប់គ្រាន់បញ្ហានេះយើងនឹងដោះស្រាយតាមផ្លូវច្បាប់ព្រោះថាការបោះឆ្នោត ទោះបីច្បាប់មានចុះឈ្មោះបោះឆ្នោតក៏ដោយ ក៏ច្បាប់អត់មានដាក់កំហិតឱ្យត្រូវតែទៅបោះឆ្នោតដែរ ព្រោះច្បាប់ស្រុកយើងក្នុងការបោះឆ្នោតក្តី ចុះឈ្មោះបោះឆ្នោតក្តីជាការស្ម័គ្រចិត្តទេ ។ ដូច្នេះករណី ថា មិនបានទៅបោះឆ្នោត គ្មានជ្រលក់ម្រាមដៃ មានកាត់ប្រាក់កំរៃ គ.ជ.ប អាចធ្វើការជូនព័ត៌មានឱ្យច្បាស់លាស់ព្រោះថាអន្តរគមន៏របស់ក្រសួងក៏អត់មានដាក់លក្ខខ័ណ្ឌថាត្រូវទៅ បោះឆ្នោត បើមិនទៅកាត់ប្រាក់កំរៃទេ ព្រោះក្នុងច្បាប់មានតែមួយទេ បើសិនជាឈប់លើសថ្ងៃដែលគេកំណត់ និងអនុវត្តតាមច្បាប់ របស់កម្មករ ។ ចំពោះយោបល់ឯក ឧត្តម អ៊ុក ភូរិ ចុងក្រោយគឺការចែកខិតប័ណ្ណ បើមើលនៅក្នុងនិតិវិធី នៃការឃោសនាការបោះឆ្នោត ការធ្វើសកម្មភាពចែកខិតប័ណ្ណក្តី ការប្រជុំក្តី នៅទីតាំងណាមួយដែលមានការគ្រប់គ្រង់ ៣ ថ្ងៃមុន ហើយគេនឹងឆ្លើយទៅវិញ ក្នុងរយៈពេល ២៤ ម៉ោង ។ បើទៅចែកក្នុងផ្សារមួយដែលមានអ្នកត្រូវស្នើសុំទៅអ្នកគ្រប់គ្រង។ ហើយបើសិនជា គេអនុញ្ញាតិឱ្យគណបក្សមួយ និង មិនអនុញ្ញាតិឱ្យគណបក្សមួយទៀត គឺខុស។

លោក **ឱក សេរីសោភក្តិ៍** អំពីបញ្ហាកម្មករ ខប់សែលបាននិយាយរឿងនេះច្រើនដងរួចមកហើយ ហើយបានសូមឱ្យតំណាងសហជីពធ្វើការជាមួយគ្នាដើម្បីលើកជាបញ្ហាសរុបជាមួយខាងវិនិយោគ អ្វីដែលមានជាបញ្ហាសំរាប់កម្មករក្នុងរឿងបោះឆ្នោតយើងដាក់ មួយដុំ ហើយចរចារដោយសូមជួបជាមួយខាងនិយោជក និងរាជរដ្ឋាភិបាល ដើម្បីពិភាក្សានិងដោះស្រាយជាមួយគ្នាតែម្តងព្រោះជាក់ស្តែង ដូចជានៅពេលដែលខាងក្រសួងបានសូមច្បាប់ដើម្បីឱ្យកម្មករទៅបោះឆ្នោត ប៉ុន្តែដល់គាត់មិនបានទៅបោះឆ្នោត ទី ១ ច្បាប់មិនបង្ខំទេ យើងបោះក៏បានមិនបោះក៏បាន ប៉ុន្តែចំពោះនិយោជក ដែលត្រូវបិទរោងចក្រនោះគឺត្រូវខាតលុយ និងសេដ្ឋកិច្ច ។ យើងសុំច្បាប់ដើម្បីទៅបោះឆ្នោត ប៉ុន្តែបើមិនបានទៅបោះឆ្នោត ដូច្នេះវាខុសពីច្បាប់ដែលដាក់បញ្ញត្តិមក ដូច្នេះទើបយើងត្រូវចរចារគ្នា ។ ចំពោះប្រាក់កំរៃសំរាប់ធ្វើដំណើរទៅ គឺគាត់បិទបញ្ជីនៅថ្ងៃ ៣១ ហើយជាទំលាប់បើកប្រាក់ឱ្យកម្មករ នៅថ្ងៃ ៧ រហូតដល់ ១២ ហើយឥលូវបង្ខំឱ្យគាត់បើកប្រាក់ដល់កម្មករនៅថ្ងៃ ទី ១ ទោះគាត់ចង់យ៉ាងណាក៏មិនបានដែរ ហើយបើចង់ខ្ចីប្រាក់ឬបើកប្រាក់ទៅមុនទាន់តែយើងចរចារជាមួយគាត់ជាមុនដើម្បីឱ្យគាត់ធ្វើការទាន់ព្រោះវាជាប្រព័ន្ធគណនេយ្យ ហើយក្រសួងក៏មានគោលនយោបាយច្បាស់លាស់ដើម្បីឱ្យនិយោជកត្រៀមគណនេយ្យរបស់គាត់ជាមុនបើសិនយើងសំរេចដូច្នោះ។ លោកជឿជាក់ថាបើគ្មានការចរចារ បញ្ហានៅតែជាបញ្ហាដដែល និងគ្មានដំណោះស្រាយឡើយ ។ បើឱ្យ គ.ជ.ប ដោះស្រាយជូនលោកគិតថាដោះស្រាយមិនចេញទេទាល់ តែកម្មកររួមទាំងអស់គ្នាជជែកគ្នារកជំហររួម បន្ទាប់មកយកទៅជជែកជាមួយនិយោជកដែលគាត់ជំហររួមរបស់គាត់ដែរ ហើយខាងរាជរដ្ឋា

ភិបាល ក្រសួងការងារនឹងអង្គុយពិភាក្សាជាមួយគ្នាជាត្រីកោណ ។ លោកសូមឱ្យមានការជជែកពិភាក្សាគ្នាពិតលូវទៅព្រោះ ប្រហែលជា ៦ ទៅ ៧ ខែទំរាំតែបានដំណោះស្រាយសំរាប់កម្មកររបស់យើងទាំងអស់គ្នា ។

## ០៣. ការអប់រំករណីពិការភាព និង ការខារបោះឆ្នោត

លោក **ង៉ិន សៅវ័ត្ត** នាយកប្រតិបត្តិនៃអង្គការជនពិការកម្ពុជា ជាអង្គការតំណាងជនពិការគ្រប់ប្រភេទមានគោលដៅកែប្រែទស្សនៈអវិជ្ជមានរបស់បងប្អូនជនពិការ ដើម្បីបំបាត់ការរើសអើងមកលើជនពិការ ។ លោកសូមបញ្ជាក់ផងដែរថា សព្វថ្ងៃនេះអង្គការជនពិការមានសមាជិកចំនួន ៧០០០នាក់ ដែលជាសមាជិកពេញសិទ្ធិ ហើយបានពឹងផ្អែកទៅលើម្ចាស់ជំនួយជួយឧបត្ថម្ភក៏ដូចជាថវិការរបស់សមាជិកភាពឧបត្ថម្ភដល់អង្គការជនពិការរបស់យើង។ ប៉ុន្តែចំនួននៃជនពិការ លោកសង្កេតឃើញមានច្រើនមែនទែននៅក្នុងនោះបើតាមស្ថិតិនៃក្រសួងផែនការណ៍ថាមានតែ ២ ឬ ៣ ភាគរយប៉ុណ្ណោះ ប៉ុន្តែបើតាមការស្រាវជ្រាវរបស់ World Bank ឃើញ ៨ ទៅ ១៥ ភាគរយនៃចំនួនជនពិការក្នុងចំនោម ១៤ លាននាក់ មាន ១៥ ភាគរយ ជាជនពិការ បើយើងគិតជាសំលេងឆ្នោតច្រើនបើបងប្អូនជនពិការបានទៅចូលរួមបោះឆ្នោត មានលក្ខណៈសេរីដូចប្រទេសជឿនលឿននៅលើពិភពលោក គឺថាជនពិការមិនចាំបាច់ដឹកដៃទៅបោះឆ្នោតនោះទេ គឺខ្លួនគាត់អាចមានលក្ខណៈឯករាជ្យដោយខ្លួនគាត់តែម្តង គឺបោះឆ្នោតដោយប្រអប់ឆ្នោតធ្វើជាអក្សរស្ទាបគឺគាត់អាចដឹងថាតើគណបក្ស ក ឬ ខ ដែលគាត់ស្រលាញ់ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាយើងមិនទាន់មាននៅឡើយទេ ។ លោកឆ្លៀតឱកាស សូមថ្លែងអំណរគុណដល់ គជប ដែលបានរៀបចំ មានការដាក់ជាភាសាសញ្ញាដល់ជនពិការ គរ ថ្លង់ ផងដែរ នេះជាសញ្ញានៃការរីកចំរើនមែនទែន ប៉ុន្តែយើងនៅតែមានការខ្វះខាតទាក់ទងនឹងផ្លូវចេញចូលការទៅបោះឆ្នោតអាទិភាពនៃការបោះឆ្នោតរបស់ជនពិការត្រូវបានឱ្យគេផ្តល់ឱ្យទូទៅ ។ ទាក់ទងនឹងគណបក្សទាំងអស់ លោកសូមសំណូមពរផងដែរ ដោយសារតែចំនួនជនពិការច្រើន ប្រសិនបើគណបក្សនិមួយៗពុំបានដាក់បញ្ចូលគោលនយោបាយស្តីអំពីបញ្ហាពិការភាពនៅក្នុងគណបក្សរបស់ខ្លួននោះទេមានន័យថាគណបក្សនោះបានបាត់បង់សំលេង ។ ជនពិការក៏ជាមនុស្សម្នាក់ដែរ ហើយមនុស្សម្នាក់មានសន្លឹកឆ្នោតម្នាក់ផងដែរ តែប្រសិនបើអស់លោកភ្លេចអំពីគោលការណ៍ ឬ គោលនយោបាយស្តីអំពីបញ្ហាពិការភាពក្នុងគណបក្សរបស់លោកនោះ លោកជឿជាក់ថាជនពិការនឹងសំលឹងមើលថាតើ គណបក្សណាដែលបានគិតគូរអំពី ជនពិការ។ ផ្ទុយមកវិញបើក្នុងករណីយើងផ្តល់អាទិភាពដល់គាត់លោកជឿថាជាឱកាសមួយល្អបំផុតដល់បងប្អូនជនពិការ។ នៅក្នុងប្រទេសយើងសព្វថ្ងៃបើយើងបានបង្កើតគណកម្មាធិការមួយដែលមានការសំរបសំរួលពីអង្គការ **Comfrel** ដើម្បីឱ្យបងប្អូនជនពិការរបស់យើងមានលទ្ធភាពក្នុងការសង្កេតការណ៍បោះឆ្នោតឈរឈ្មោះឱ្យគេបោះឆ្នោត ហើយលោកសូមសំណូមពរមួយចំនួន ដោយសារតែគោលនយោបាយមួយចំនួនថែងឡើង ចងជើងជនពិការតែម្តង ដោយមិនឱ្យឈរឈ្មោះបោះឆ្នោត ឬ មិនឱ្យទៅបោះឆ្នោតបានតែម្តង គឺមានលក្ខណៈពិបាកទោះជារដ្ឋធម្មនុញ្ញបានចែងថាប្រជាពលរដ្ឋមានសិទ្ធិស្មើគ្នា ប៉ុន្តែបើយើងងាកសំលឹងមើលមកក្នុងបញ្ហានៅក្នុងប្រទេសកម្ពុជា បញ្ហានៅតែជាបញ្ហាផ្លូវចេញចូលរបស់ជនពិការគ្មានទេ ដូចជាអគារមួយចំនួនដាក់ស្តែងដូចជា គណកម្មាធិការបោះឆ្នោតយើងតែម្តងកន្លែងប្រជុំយើងឡើងមកដល់ជាន់លើតែម្តង បើសិនជាជនពិការឡើងគាត់មានការវេទនាខ្លាំង តែដោយសារតែលោកស្ទិតជើងតែម្ខាង លោកអាចឡើងរួច ចុះបើជនពិការប្រើរទេះរុញ នេះក៏ជាការសំរបសំរួលមួយដែរបើយើងអាចដាក់អាគារខាងក្រោម បើជនពិការមិនចូលរួមជារឿងរិតតែប្រសើរថែមទៀត ។ នេះឱកាសដ៏ល្អផងដែរ ដែលខប់សែល មានអនុញ្ញាតឱ្យលោកក៏ដូចជាសមាជិករបស់លោកបានចូលរួមនិងផ្តល់អនុសាសន៍អំពីផលវិបាក នៃជនពិការនៅក្នុងប្រទេសកម្ពុជារបស់យើង ទោះជាមានការលំបាកច្រើនក៏គាត់មានឆន្ទះចង់ចូលរួមនៅក្នុងបញ្ហានយោបាយព្រោះថា សិទ្ធិមនុស្ស

គឺទទួលសិទ្ធិស្មើគ្នា តែប្រសិនបើសិទ្ធិនយោបាយក៏ជាសិទ្ធិមួយដែរគឺគាត់គិតទៅលើគណបក្សណាដែលគាត់ស្រលាញ់គណបក្សណាដែលយកចិត្តទុកដាក់នឹងគាត់ គាត់នឹងគិតគូរអំពីគណបក្សនោះផងដែរ។ ហើយអ្វីដែលខាងលោកសំណូមពរនោះគឺថាយើងមិនមែនចង់ឱ្យមានការកែប្រែនៅពេលបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ខាងមុខនេះទេ គឺយើងចង់ឱ្យមានការកែប្រែ នៅពេលបោះឆ្នោតជាតិ នៅឆ្នាំក្រោយដើម្បីធ្វើយ៉ាងណាឱ្យលិទ្ធិប្រជាធិបតេយ្យក៏ដូចជាសិទ្ធិនៃការទទួលសិទ្ធិស្មើគ្នារវាងជនមិនពិការ និងជនពិការភាគច្រើនយើងតែងតែនិយាយថា ចាស់ជរា ជនគ្មានទីពឹង ។

លោក **សយ សុខន** សូមថ្លែងអំណរគុណដល់លោកប្រធានអង្គប្រជុំដែលបានដាក់ប្រធានបទនេះឡើង ហើយលោកក៏បានថ្លែងអំណរគុណដល់ ឯកឧត្តមអគ្គ ដែលបានដាក់ spot ជាភាសារសញ្ញា។ លោកសូមសំណូមពរសំរាប់ការបោះឆ្នោតជាតិ ២០០៨ បញ្ហាដែលបានជួបប្រទះគឺលោកបានអានសៀវភៅមួយគឺ សៀវភៅណែនាំគណកម្មាការរៀបចំការបោះឆ្នោត និងគណកម្មាការការិយាល័យបោះឆ្នោត នៅក្នុងវគ្គទី ៤នៃការប្រព្រឹត្តិទៅនៃអ្នកបោះឆ្នោតជ្រើសរើសឃុំសង្កាត់ និងថ្ងៃបោះឆ្នោត ប្រធានការិយាល័យបោះឆ្នោត នៅទំព័រទី ១២ ត្រង់ចំណុចទី ១០ ពាក្យដើមនៅសៀវភៅណែនាំដល់គណកម្មាការការិយាល័យបោះឆ្នោតមាននិយាយថាផ្តល់អាទិភាពដល់ព្រះសង្ឃ ចាស់ជរា ស្ត្រីមានផ្ទៃពោះ អ្នកមានជំងឺ និងជនពិការដែលមិនអាចទៅបោះឆ្នោតដោយខ្លួនឯងបាន ព្រមទាំងអ្នកអមដំណើរជនពិការនោះនិងឈរនៅក្នុងជួរបន្តបន្ទាប់ឱ្យចូលទៅក្នុងការិយាល័យបោះឆ្នោត ។ លោកគិតថានៅត្រង់ចំនុចនេះមានការបំបិទខ្លះ ផ្តល់អាទិភាពតែដល់ជនពិការភ្នែក ហើយលោកសូមឱ្យឯកឧត្តម អគ្គលេខាធិការ គជប រួមបន្ថែម សំណូមពរដូចពាក្យថាផ្តល់អាទិភាព ដល់ព្រះសង្ឃ ចាស់ជរា ស្ត្រីមានផ្ទៃពោះ អ្នកមានជំងឺ និងជនពិការគ្រប់ប្រភេទ និងឈរនៅក្នុងជួរមុខបន្តបន្ទាប់ឱ្យចូលក្នុង ការិយាល័យបោះឆ្នោត ពីព្រោះកាលពីប្រជុំកាលពីខែមុន ឯកឧត្តមថានឹងយកទៅពិចារណាថានឹងឱ្យអ្នកពិការភ្នែកគូសដោយខ្លួនឯង ដោយសំងាត់ បើសិនជាជនពិការភ្នែកអាចគូសសំងាត់ដោយខ្លួនឯងបាន លែងចាំបាច់ត្រូវការអ្នកឈរអមទៅជាមួយទៀតទេ នេះជា សំណូមពរសំរាប់ការបោះឆ្នោតនៅឆ្នាំ ២០០៨ ។ ចំណែកបញ្ហាមួយទៀតគឺជនពិការពុំបានក្លាយខ្លួនជាគណកម្មាការ និងគណកម្មាការការិយាល័យបោះឆ្នោតឃុំសង្កាត់ ខេត្ត-ក្រុង ជាក់ស្តែងដូចជាលោកក្រលេកមើលសកម្មភាពមួយចំនួនជនពិការក៏អាចផ្តល់ព័ត៌មាន ដល់គណបក្សនេះ សកម្មភាពតួនាទីនៅក្នុង CEC តែម្តង ចែកប័ណ្ណលោកគិតថាជនពិការអាចជិះម៉ូតូបាន ឡានបានដូចគ្នាទាំងអស់ ជាពិសេសអ្នកនៅក្នុងការិយាល័យដូចជាអ្នកជ្រលក់ទឹកថ្នាំ គាត់ក៏អាចធ្វើបានដោយមិនចាំបាច់ បណ្ឌិត អនុបណ្ឌិត បរិញ្ញាអ្វីទេ ចំពោះ មន្ត្រីរៀបចំសណ្តាប់ធ្នាប់ ជនពិការក៏អាចរៀបចំឱ្យឈរជាជួរបានគឺថាមានគំនិតធ្វើបានដូចគ្នាទាំងអស់ ។ លោកសំណូមពរនេះគឺដើម្បី លើកទឹកចិត្តដល់កុមារពិការដែលកំពុងតែបន្តការសិក្សានោះព្រោះភាគច្រើនគេបានឱ្យតំលៃទៅលើកុមារពិការថាខំរៀនធ្វើអ្វី ឯងមិន បានធ្វើធំស្អី រៀនចេះយ៉ាងម៉េចក៏មិនបានធ្វើដែរគឺគេមិនដែលយកជនពិការធ្វើនាយករដ្ឋមន្ត្រី នេះជាចំនុចដែលធ្វើឱ្យផ្អាក់ដំណើរការ រើសអើងនៅក្នុងការងារ អ្វីៗជនពិការតែងតែមានការចូលរួមទាំងអស់ព្រោះជនពិការក៏ជាជនមួយរូបដូចគ្នា ហើយបោះឆ្នោតក៏មួយសន្លឹកដូចគ្នាដែរ ។ សំណូមពរឱ្យគណកម្មារៀបចំការបោះឆ្នោតប្រចាំនៅប្រទេសកម្ពុជាមេត្តាផ្តល់អាទិភាពដល់ជនពិការឱ្យបានក្លាយខ្លួនជាគណកម្មាការរៀបចំការបោះឆ្នោត និងបុគ្គលិកគណកម្មាការការិយាល័យបោះឆ្នោតផងនៅពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ ២០០៨ ខាងមុខនេះ ។ បញ្ហាមួយទៀតគឺទាក់ទងនឹងច្បាប់ក្រសួងមហាផ្ទៃ ដោយសារថ្ងៃនេះ លោកតំណាងប្រធានក្រសួងមហាផ្ទៃមិនបានមក លោកសូមផ្តាំផ្ញើតាម គជប ថាស្តីអំពីការគ្រប់គ្រងឃុំ-សង្កាត់មានការរើសអើង មកលើជនពិការតែម្តង ជំពូកទី២ មាត្រាទី ១៤ និយាយថាមានអ្នកដែលអាចឈរឈ្មោះឱ្យគេបោះឆ្នោតបានលុះត្រាតែមានលក្ខណៈ សម្បត្តិគ្រប់គ្រាន់លក្ខណៈដែលបាន កំណត់នៃការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត គឺថាសូមដាក់ច្បាប់ដោយមិនគិតពីកាយសម្បទា នេះជាសញ្ញាមិនឱ្យជនពិការចូលរួម ក្នុងការអភិវឌ្ឍន៍ ឃុំរបស់ខ្លួនបានទេ ។ មាត្រាទី ១៦ និយាយថាសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ដែលបាត់បង់សមា

ជិកភាពរបស់ខ្លួន ទៅតាមករណីមួយក្នុងចំនោមករណីខាងក្រោម នៅចំណុចទី ២ កថាខ័ណ្ឌទី ៤ សាម៉ីខ្លួនបាត់បង់ សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ដូច្នេះលោកសំណូមពរសូមឱ្យឯកឧត្តមធ្វើយ៉ាងណាជួយឱ្យធ្វើយ៉ាងណាកុំឱ្យមានការរើសអើងដល់ជនពិការពាក់ព័ន្ធ នឹងច្បាប់គ្រប់គ្រងឃុំ-សង្កាត់នេះព្រោះជនពិការក៏មានសមត្ថភាពផងដែរ ។

កញ្ញា **ហេង ចន្ធី** សំណូមពរសូមឱ្យមានរបៀបវារៈនេះនៅអង្គប្រជុំលើកក្រោយទៀត គឺថាសូមបន្តរបៀបវារៈជារៀងរាល់ខែ។

លោក **ឱក សេរីសោភ្គ័** មិនទាន់ហ៊ានសន្យាថានឹងមានរបៀបវារៈជារៀងរាល់ខែទេ ព្រោះរបៀបវារៈទាល់តែមានជាបញ្ហាយើងដឹងស្រាប់ហើយថាការប្រជុំ ឧប់សែលនេះគឺ យើងលើកយកមកនូវអ្វីដែលជាបញ្ហាទាក់ទងនឹងការបោះឆ្នោត ។ ដោយយល់ថាបញ្ហាជនពិការនេះយើងមិនបានចាប់អារម្មណ៍យូរណាស់មកហើយ និងគួរតែដល់ពេលមួយដែលប្រជាពលរដ្ឋខ្មែរនិងគ្រប់អង្គការទាំងអស់រួមទាំងអង្គការ CDRI នេះផងដែរចាប់ផ្តើមគិតដល់ការលំបាករបស់ជនពិការដែលជាប្រជាពលរដ្ឋម្នាក់ពេញសិទ្ធិ ១០០ ភាគរយក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការចូលរួមនយោបាយ។ ដូច្នេះហើយទើបយើងដាក់ក្នុងរបៀបវារៈក៏ប៉ុន្តែបើសូមឱ្យដាក់រាល់ពេលគឺយើងចេះតែដាក់បានតែអាចក្លាយជាច្រំដែល ។ លោកគិតថាការយកចិត្តទុកដាក់របស់សង្គមជាតិទៅលើបញ្ហាជនពិការអាស្រ័យទៅលើសង្គមជាតិនោះប្រាកដហើយ ហើយក៏អាស្រ័យទៅលើជនពិការខ្លួនឯងផងដែរដែលខំលើកយកបញ្ហាមក ខំមកចូលរួមនិងខំរៀបចំជាក្រដាសស្នាម ហើយលោកក៏សូមឱ្យផ្តល់អត្តសញ្ញាណចំពោះខ្លួនឯងដើម្បីឱ្យគេស្គាល់និងចាប់អារម្មណ៍ ។ ខាងឧប់សែលនឹងផ្តល់លទ្ធភាពទាំងអស់នេះជូនទៅថ្ងៃអនាគត ។ រឿងមួយដែលលោកសូមព្រោះលោកគិតថាអ្វីដែលអង្គការជនពិការ លើកយកមកគឺមិនត្រូវការពិភាក្សាទេ បើយើងបានយល់ដឹងទៅលើរឿងទាំងអស់នេះហើយ យើងនឹងចាំជួយគាំទ្របន្តទៀតគឺយើងមិនចាំបាច់មានការប្រជុំនៅក្នុងអង្គប្រជុំឧប់សែលទេ ប៉ុន្តែនៅពេលដែលមានជាបញ្ហាសូមលើកយកមកដើម្បីដោះស្រាយដូច ឯកឧត្តមអគ្គ NEC ក៏បានរៀបចំជា spot ជាពិសេសសំរាប់ជនពិការ ។ លោកចង់ឱ្យអង្គការជនពិការធ្វើរឿងមួយដោយសហការជាមួយ NEC ថាតើក្នុងចំនោម ១៥% នៃ ១៤លាននាក់ ថាស្រីមានចំនួនប៉ុន្មាន ប្រុសប៉ុន្មាន និង ពិការរបៀបយ៉ាងម៉េចខ្លះ ហើយនៅក្នុងការបោះឆ្នោះក្រុមប្រឹក្សាឃុំសង្កាត់ខាងមុខនេះថាតើជនពិការប៉ុន្មាននាក់ដែលបានអញ្ជើញទៅបោះឆ្នោត ហើយជួបប្រទះនឹងការលំបាកអ្វីខ្លះតាមស្ថានីយ៍បោះឆ្នោតដែលគួរលើកយកស្រង់ជាបញ្ជីអំពីការលំបាករបស់ជនពិការហើយ យុទ្ធនាការបោះឆ្នោតមិនបានគិតដល់ខាងឧប់សែលនឹងជួយពង្រាយព័ត៌មាននេះដើម្បីលើកកំពស់ការអប់រំអំពីពិការភាពនៅប្រទេសកម្ពុជា ។

លោក **ង៉ិន សៅរ័ត្ន** សូមសំណូមពរខ្លីមួយទាក់ទងនឹងកម្មវិធីអភិវឌ្ឍន៍មួយចំនួនធំនៅក្នុងប្រទេសកម្ពុជាយើងនេះ បើសិនអង្គការទាំងនោះគ្មានជំនាញធ្វើការជាមួយជនពិការ ហើយលោកសូមឆ្លៀតឱកាសនេះអំពាវនាវ ប្រសិនបើគណបក្សណាត្រូវការបណ្តុះបណ្តាលដល់សមាជិក សមាជិការរបស់ខ្លួនអំពីបញ្ហាពិការភាព អង្គការជនពិការកម្ពុជានឹងផ្តល់ជូនគ្រប់គណបក្សក៏ដូចជាអង្គការដែលធ្វើការអភិវឌ្ឍន៍លើប្រទេសកម្ពុជាយើងទាំងមូលតែម្តង ។

ឯកឧត្តម **ទេព នីថា** លោកសូមថ្លែងអំណរគុណដល់អង្គការជនពិការដែលបានលើកឡើង នូវការលំបាករបស់ជនពិការ។ ជារួមនៅលើនិតិវិធី គជប តែងផ្តល់អាទិភាពដល់ជនពិការ ជាក់ស្តែងដូចបានសរសេរក្នុងនិតិវិធី បង្កលក្ខណៈដល់ជនពិការដែលបានចូលរួមបោះឆ្នោត ឬចុះឈ្មោះបោះឆ្នោតដោយឱ្យមានអ្នកទៅតាមជាមួយ នេះជាការបង្កលក្ខណៈមួយតែមិនបានសំដៅទៅលើពិការភ្នែក ឬត្រចៀកទេ អ្នកណាទៅមិនបានមានគេជូន យើងអនុញ្ញាតឱ្យទៅទាំងពីរ ។ បញ្ហាមួយដែលលោកបានដោះស្រាយហើយទាក់ទងនឹងភាសារសញ្ញា គឺលោកបានបញ្ចូលទៅក្នុង spot ហើយដោយឡែកកម្មវិធីផ្សេងទៀត គជប ពុំមានលទ្ធភាពធ្វើទេ ជាក់ស្តែងដូចជាការអប់រំផ្សេងៗពីនិតិវិធីនៃការបោះឆ្នោត គឺវែងពេកហើយការផលិតក្នុងរយៈពេលខ្លី បញ្ហាទី ២ ទីកន្លែងសំរាប់ជនពិការទៅបោះឆ្នោត

ដោយមានរទេះ គ.ជ.ប ក៏បានណែនាំនៅក្នុងការបណ្តុះបណ្តាលនេះហើយ ទោះបីមិនទាន់មានជណ្តើរដើម្បីឱ្យគាត់ឡើងទៅលើក៏បង្កលក្ខណៈឱ្យសន្តិសុខ២នាក់នៅខាងក្រៅលើករទេះគាត់ឡើងទៅលើដើម្បីអាចទៅបោះឆ្នោតបានករណីនេះមានចំនួនតិចទេ។ ចំពោះការបោះឆ្នោតសំរាប់ជនពិការដែលងងឹតភ្នែកដែលមានរបៀបបោះឆ្នោតដោយស្ទាបនោះ គ.ជ.ប នឹងពិនិត្យលទ្ធភាពនៅឆ្នាំ ២០០៨ ការងារនេះគឺទាក់ទងនឹងសំភារៈពិនិត្យតិចតួច មិនថ្លៃទេ គជប អាចធ្វើបានក៏ប៉ុន្តែសំខាន់គឺការអប់រំជនពិការ ដែលងងឹតភ្នែកថាតើនរណាអប់រំគាត់ គណបក្សនយោបាយ ឬ គជប? ជាទូទៅ គជប អប់រំជាលិខិតទូទៅតែមិនអាចយកជនពិការម្នាក់ៗដែលងងឹតភ្នែកមកអប់រំបានទេ ហើយលោកជឿជាក់ថាគណបក្សនយោបាយក៏មិនបានយកចិត្តទុកដាក់លើបញ្ហានឹងខ្លាំងដែរព្រោះថាជនពិការមានភាគរយតិច ដូច្នេះទាក់ទងនឹងការអប់រំទាំងអស់គ្នា ទាំងអង្គការជនពិការ និង ទាំងខាង គជប ព្រោះថា ជនពិការបើសិនជាគាត់ចុះឈ្មោះបោះឆ្នោត គឺបោះឆ្នោតរួមជាមួយអ្នកដទៃទៀតដែរដូចនេះមានការលំបាកដែរ ។ ចំពោះការចូលបំពេញការងាររបស់បងប្អូនជនពិការនៅក្នុងគណកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចថាបណ្តាលមកពី គជប មិនបង្ករលក្ខណៈងាយស្រួលក៏បាននិងថាបងប្អូនជនពិការមិនបានទៅដាក់ពាក្យក៏បាន ព្រោះនៅក្នុងសេចក្តីប្រកាសមិនបានប្រកាសថាមានកាយសម្បទាមិន គ្រប់គ្រាន់មិនអោយដាក់ពាក្យទេ ប៉ុន្តែដូចដែលឯកឧត្តមបានជំរាបជូនរួចហើយ គណៈកម្មាធិកាការិយាល័យបោះឆ្នោតមិនត្រឹមតែយាមទេគឺមានការងារលើកដាក់ការងារដឹកជញ្ជូនដែលត្រូវប្រើកំលាំងប្រើកាយសម្បទា ហើយចំពោះការងារការិយាល័យ គឺមានតែនៅពេលបោះឆ្នោតប៉ុណ្ណោះរួចទេ ហើយសុទ្ធតែជាការងារលើកដាក់ទាំងអស់ ឯកឧត្តមជឿថាការងារខ្លះជនពិការអាចធ្វើបាន ដូចនេះហើយប្អូនជនពិការពិនិត្យមើលការងារដែលអាចមានលទ្ធភាពដាក់បាន ក៏សូមដាក់ដូចគេទៅជាទូទៅ គជប ពិចារណាតាមលទ្ធភាពជាក់ស្តែងទាំងអស់ដោយស្មើគ្នា ។ ឯកឧត្តមនឹងយកសំណើរទាំងអស់ទៅពិនិត្យឡើងវិញនៅពេលជ្រើសរើសបុគ្គលិកបំពេញការងារលើកក្រោយហើយក៏សូមអោយប្អូនជនពិការខ្លួនឯងទី១ ពិនិត្យមើលសមត្ថភាពខ្លួនឯង ។ ទី២ មើលថាតើការងារដែលខ្លួន អាចធ្វើបាន ។

## ០៤.បញ្ហាដែលនៅសេសសល់ មួយសប្តាហ៍មុនពេលបោះឆ្នោត

លោក **គឹង ម៉ៅ** សមាជិកគណបក្សសម រង្ស៊ី ព្រួយបារម្ភស្តីអំពីសេចក្តីណែនាំរបស់ គជប លេខ១៣១ ស្តីអំពីការខុសឈ្មោះតិចតួច ។ លោកបារម្ភថានៅការិយាល័យមួយចំនួនមិនយល់ពីបញ្ហានេះ ដោយសារតាមលោកពិនិត្យមើល CEC មួយចំនួនមិនទាន់មានចំនុច លេខ១៣១ ផង លោកក៏បានហ្វូតូកូពីអោយតែម្តង លោកបារម្ភថានៅពេលដែលបោះឆ្នោតនឹងខុសឈ្មោះបន្តិចបន្តួចគឺមិនអោយបោះឆ្នោត ដូចនេះសូមធ្វើអោយប្រាកដថាព័ត៌មានទាំងអស់បានទៅដល់ដៃពួកគាត់ ។ បញ្ហាទី២ បញ្ហារូបថតដែលនៅតែជាបញ្ហាដដែលដោយសារតែទំរង់ ១០១៨ គាត់មិនមានរូបថត ។

លោក **អ៊ុក គឹមហាន** បានលើកឡើងពីបញ្ហាដែលបានចោទសួរតាមបណ្តាខេត្ត/ក្រុង មកច្រើនដែរ ទី១ គឺបញ្ហាគូសសន្លឹកឆ្នោត ថាតើការគូសធ្វើដូចម្តេច ? គជប បានណែនាំអោយគូសសញ្ញា ធិក ប៉ុន្តែប្រជាជនបានសួរថាបើពួកគាត់គូសសញ្ញាផ្សេងបាន រឺ ទេ ដូចជាសញ្ញា ដក មូល បូក ជាដើម ដែលមិនបានចែងក្នុងនិតិវិធីដែល គជប បានចែង លោកមានការព្រួយបារម្ភនៅពេលដែលរាប់សន្លឹកឆ្នោតមានការប្រទាញប្រទង់គ្នាថាតើសន្លឹកឆ្នោតនឹងយកជាការបាន រឺ ទេព្រោះមិនបានចែងក្នុងនិតិវិធីរបស់ គជប ។ ទី២ គឺការប្រើប្រាស់ប៊ិច ព្រោះពេលបោះឆ្នោតព្រឹទ្ធសភាលើកលែងតែខ្មៅដៃទេដែលមិនអាចយកជាការបាន ប៉ុន្តែនៅពេលបោះឆ្នោតក្រុមប្រឹក្សា ឃុំសង្កាត់នេះ និតិវិធីបានចែងច្បាស់ ហើយថាអ្នកបោះឆ្នោតពេលចូលក្នុងបន្ទប់សំងាត់ ត្រូវយកប៊ិចដែលចងខ្សែនៅក្នុងនោះគូស ពួកគាត់សួរថាតើពួកគាត់អាចយកប៊ិចដែលពួកគាត់យកទៅជាមួយដែលមានពណ៌ផ្សេងគូសបានដែរឬទេ ?

លោក **ខៀវ សួន** ប្រធាននាយកដ្ឋាន បានចោទសួរទៅ គជប អំពីបញ្ហានៅពេលដែលរាប់សន្លឹកឆ្នោត លោកមានចំងល់ថានៅពេលដែលមានការតវ៉ាគ្នានៅពេលមានភាពមិនប្រក្រតីកើតឡើង ឧបមាថានៅឃុំមួយគណបក្សមួយសុំអោយរាប់សន្លឹកឆ្នោតសា

ថ្មី តើខាង CEC ឬខាង គជប អាចសំរេចបានទេអោយរាប់សន្លឹកឆ្នោតឡើងវិញបើសិនជាមានការលំអៀងកើតឡើង ហើយបើសន្លឹកឆ្នោតនឹងចូលទៅក្នុងហឹបទៅបាត់ហើយ ។

លោក **នូ ហែមព្រហ្មវីរៈ** មានការព្រួយបារម្ភរបស់លោកនោះគឺរាត្រីឆ្កែព្រូស មានន័យថាគឺយប់នៅក្នុងថ្ងៃ ស តើ គជប មានវិធានការយ៉ាងណាកុំអោយមានតែម្តង ។ មួយទៀតនៅថ្ងៃបោះឆ្នោតទាក់ទងទៅនឹងផ្លាកសញ្ញារបស់គណបក្សនយោបាយនិមួយៗ ឧទាហរណ៍ថាផ្លាកសញ្ញាគណបក្សហាមមិនអោយមាននៅចំងាយ ១០០ ម៉ែត្រពីស្ថានីយ៍បោះឆ្នោត បើសិនជាផ្លាកសញ្ញាគណបក្សនៅចំងាយលើសពី ១០០ ម៉ែត្រ ដូចជាចំងាយ ១០១ ម៉ែត្រ ហើយមើលឃើញតើយ៉ាងម៉េចដែរ ? សូម គជប ជួយបកស្រាយត្រង់ចំណុចនេះ ។

លោក **អ៊ុក គឹមហាន** បានលើកបន្ថែមចំណុចមួយអំពីការគូសតាមការណែនាំគឺអោយអ្នកដែលទៅបោះឆ្នោតគូសតែលើប្រអប់៤ ជ្រុងទ្រវែងនៃគណបក្សមួយនូវគំនូសមួយ បើសិនជាពួកគាត់គូសលើគំនូស ពីរ បី វី បួន នៅលើប្រអប់តែមួយ តើសន្លឹកឆ្នោតនោះយកជាការបានដែរ ឬទេ ? លោកសូមអោយ គជប ជួយបកស្រាយ ។

លោក **តារា ឫទ្ធិ** មកពីអង្គការ NICFEC លោកសង្កេតឃើញការឃោសនានៅខេត្តកំពង់ចាម ពេលដែលពួកគាត់ចុះទៅឃោសនាជួបប្រជាពលរដ្ឋ គាត់សុំប័ណ្ណព័ត៌មានពីប្រជាពលរដ្ឋ ហើយគូស ធិក មួយនៅលើប័ណ្ណព័ត៌មានរបស់ប្រជាពលរដ្ឋ ហើយអ្នកដែលគូសនោះយើងបានស្គាល់អត្តសញ្ញាណថាជាមេឃុំ ។ លោកសូមអោយអង្គប្រជុំពិគ្រោះយោបល់គ្នាមើលថាតើករណីនេះជាការបំផិតបំភ័យដល់ប្រជាពលរដ្ឋដែរឬទេ ។ មួយទៀតទាក់ទងទៅនឹងមន្ត្រីឃុំសង្កាត់រៀបចំការបោះឆ្នោត ដែលកើតឡើងនៅក្នុងខេត្តកំពង់ចាមដែរ ដែលមន្ត្រី CEC គាត់ទៅហាមសកម្មជនរបស់គណបក្សមួយ ដែលលោកសូមមិនលើកឡើងពីឈ្មោះទេ អោយយកបដាឃោសនាមួយចេញពីទីតាំងមួយនៅជិតបឋមសិក្សាវសំព័រ ដោយអះអាងថានៅជិតការិយាល័យបោះឆ្នោត តែនៅក្នុងអំឡុងពេលការឃោសនាបោះឆ្នោតនៅឡើយទេ ។

ឯកឧត្តម **ទេព នីថា** បានមានប្រសាសន៍ថាចំណុចដែលបានលើកឡើងភាគច្រើន គជប បានបកស្រាយពីមុនរួចអស់ហើយ និង បានចាត់វិធានការមួយជំហ៊ានមុនរួចហើយ ។ ឯកឧត្តមសូមរំលឹកឡើងវិញអំពីសេចក្តីណែនាំអំពីការខុសឈ្មោះ ទោះបីឯកសារមួយចំនួនដែលទៅចែកមិនទាន់ទៅដល់ឃុំ-សង្កាត់ ក៏ដោយក៏ប៉ុន្តែយើងបានធ្វើការបណ្តុះបណ្តាលឯកសារនេះទៅជាមួយឯកសារបណ្តុះបណ្តាល ហើយឯកសារទាំងនេះមិនទាន់ទៅដល់ការិយាល័យបោះឆ្នោតទេ ព្រោះការិយាល័យបោះឆ្នោតមិនទាន់រើសនៅឡើយ ឯកសារនៅគណកម្មាធិការរៀបចំការបោះឆ្នោត ហើយគណកម្មាធិការរៀបចំការបោះឆ្នោតនឹងធ្វើការបណ្តុះបណ្តាលដល់មន្ត្រីបោះឆ្នោតនឹងនៅ ថ្ងៃទី ៣០ ហើយឯកសារទាំងអស់នឹងផ្តល់ជូនគាត់នៅ ថ្ងៃនោះតែម្តង ឯកសារនេះ UNDP បានបោះពុម្ពប្រហែល ៥0000 ច្បាប់ចែកជូនតាមបណ្តាគណបក្ស និង អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដើម្បីធ្វើការផ្សព្វផ្សាយបន្តហើយជាទូទៅតាម រយៈការផ្សព្វផ្សាយដែលឯកឧមត្តបានសម្ភាសន៍តាមប្រព័ន្ធផ្សព្វផ្សាយប្រហែលជាដឹងបានគ្រប់កន្លែងអស់ហើយ ទោះបីជាឯកសារមិនទាន់ទៅដល់ក៏ដោយ វិធីចែកមិនអាចធ្វើភ្លាមបានទៅដល់ឃុំសង្កាត់ភ្លាមនោះទេ ។ បញ្ហារូបថត គជប បាននិយាយរួចហើយមិនទទួលខុសត្រូវចំពោះបញ្ហារូបថតនេះទេ គឺប្រជាពលរដ្ឋជាអ្នកទទួលខុសត្រូវខ្លួនឯង ហើយកន្លងមកមានគណបក្សមួយចំនួនបានជួយថតរូប ជូនប្រជាពលរដ្ឋ ហើយអ្នកបារម្ភនៅតែបារម្ភដដែល ប៉ុន្តែព័ត៌មាននេះឯកឧត្តមមិនបានទទួលពីគណកម្មាធិការរៀបចំការបោះឆ្នោតទេ ប៉ុន្មានថ្ងៃមុនឯកឧត្តមបានទទួលព័ត៌មានពី ខេត្ត រតនៈគីរី មានគណបក្សមួយគាត់ទៅថតអោយទៀតហើយ ដូចនេះឯកឧត្តមគិតថាបើមានក៏ករណីតិចតួចដែរបញ្ហានេះ។ ចំពោះការគូសសន្លឹកឆ្នោត គ.ជ.ប ជាទូទៅ អប់រំប្រជាពលរដ្ឋអោយធ្វើអោយត្រូវសញ្ញាដែលយើងចង់បានអោយត្រូវ ប៉ុន្តែការអនុគ្រោះនៅពេលគូសខុសរបៀបណានោះជារឿងដែលត្រូវអប់រំអ្នករាប់សន្លឹកឆ្នោត ឬ អ្នកពិនិត្យមើលសន្លឹក

ឆ្នោត នៅការិយាល័យបោះឆ្នោត គជប បានធ្វើប័ណ្ណប្រកាសមួយដែលមាន២សន្លឹកធំ៧ ដែលដាក់សន្លឹកឆ្នោតមិនបានការ ។ អ្វីដែលគ្មាននៅក្នុងសន្លឹកឆ្នោតមិនបានការគឺបានការទាំងអស់ ហើយប័ណ្ណប្រកាសនេះនឹងបញ្ជូនទៅការិយាល័យបោះឆ្នោតជាមួយសំភារៈបោះឆ្នោតទៅគ្រប់ការិយាល័យបោះឆ្នោត ។ ចំពោះការគូសសន្លឹកឆ្នោតយើងណែនាំអោយពួកគាត់គូសប៊ិចដែលយើងដាក់អោយនៅក្នុងបន្ទប់សំងាត់ ប៉ុន្តែបើសិនជាករណីគាត់គូសបិចរបស់គាត់ក៏មិនមានបញ្ហាអ្វីដែរលើកលែងតែគំនូសនោះធ្វើអោយដឹងថាគាត់ជាអ្នកណា។ ការគូសនៅក្នុងប្រអប់តែមួយច្រើនដងមិនមែនជាបញ្ហាអ្វីទេ លើកលែងតែគាត់គូសនៅលើប្រអប់២ផ្សេងគ្នា ឬគាត់ គូសនៅក្នុងប្រអប់២ដង ហើយគូសនៅក្រៅម្តងទៀតទើបទុកជាសន្លឹកឆ្នោតមិនបានការ ហើយបញ្ហានេះនឹងមានការដោះស្រាយផ្សេងទៀត ឧទាហរណ៏ថានៅពេលប្រធានការិយាល័យរាប់សន្លឹកឆ្នោតឡើងថាសន្លឹកឆ្នោតនេះគាំទ្រ គណបក្ស ក ហើយលើកបង្ហាញទាំងអស់គ្នាទៅ ហើយនៅពេលមានអ្នកណាតវ៉ា គេទុកសន្លឹកឆ្នោតនោះមួយដុំសិនមិនទាន់រាប់បញ្ជូលទេ គេរាប់សន្លឹកឆ្នោតណាដែលត្រឹមត្រូវហើយដាក់តាមគណបក្សរៀងខ្លួន ហើយបានគេយកសន្លឹកឆ្នោតដែលសង្ស័យមកជជែកគ្នាម្តងទៀត និងពេលជជែកគ្នានេះយើងមានសិទ្ធិតវ៉ា ហើយការសំរេច គឺផ្តល់អាទិភាពទៅដល់ប្រធានការិយាល័យបោះឆ្នោត ក្នុងករណីដែលប្រធានការិយាល័យសំរេចហើយអ្នកតវ៉ាមិនពេញចិត្តនឹងការសំរេចនោះ ទី១ គាត់អាចចុះនៅក្នុងរបាយការណ៏កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតទើបគេកត់អោយគាត់ បើគាត់មិនចុះហត្ថលេខាទេគេមិនកត់នៅក្នុងកំណត់ហេតុអោយគាត់ទេ។ ករណីទី២ គាត់អាចប្តឹងតវ៉ាទៅគណកម្មាធិការរៀបចំការបោះឆ្នោតរហូតដល់ព្រឹកឡើងថ្ងៃបន្ទាប់ត្រឹមម៉ោង ១១ព្រឹក ហើយការប្តឹងមានអោយអាទិភាពប្តឹងតែទៅប្រធានការិយាល័យរាប់សន្លឹកឆ្នោតតែមួយទេ ធ្វើបែបនេះគឺមិនចង់អោយមានការរាំងស្ទះ គឺផ្តល់សិទ្ធិមួយអោយគាត់នៅក៏រិតហ្នឹង ព្រោះការសំរេចរបស់គាត់មិនមែនជាការសំរេចស្ថាពរទេ នៅមានការសំរេចទៅថ្នាក់ឃុំថែមទៀតនិងធ្វើការពិនិត្យទៅតាមករណីជាក់ស្តែងបើករណីមិនប្រក្រតីដែលកើតឡើងធ្ងន់ធ្ងរ យើងនឹងលើកយោបល់ទៅគណកម្មការខេត្ត ហើយបដិសេធលទ្ធផលនោះចោល ឬ គាត់មានសិទ្ធអាចសំរេច រាប់សន្លឹកឆ្នោតនៅកន្លែងដែលមានភាពមិនប្រក្រតីនោះឡើងវិញបាន។ ចំពោះការប្រើទូរទស្សន៏នៅពេលរាប់សន្លឹកឆ្នោតយើងមិនទាន់មានលទ្ធភាពទេ នៅពេលលើកសន្លឹកឆ្នោត ក្នុងករណីដែលគាត់លើកលឿនពេកយើងអាចសុំអោយគាត់រាប់យឺតបន្តិចបានព្រោះថានៅទល់មុខគ្នាទាំងអស់ទេ ។ បញ្ហាមួយទៀតដែល YCC លើកឡើងអំពីថ្ងៃមុនពេលបោះឆ្នោត ឯកឧត្តមសូមអោយពិនិត្យមើលឡើងវិញច្បាប់ហាមនៅមុនថ្ងៃបោះឆ្នោតមួយ ថ្ងៃមិនអោយឃោសនាបោះឆ្នោត ប៉ុន្តែច្បាប់មិនមានហាមមិនអោយជូនព័តិមានដល់ប្រជាពលរដ្ឋទៅបោះឆ្នោតទេ តែទ្រង់ទ្រាយណាមួយដែលមានការបង្ខំមានការឃោសនាគឺខុសច្បាប់ ដូច្នេះក្នុងករណីដែលគណបក្សនយោបាយដែលមានភ្នាក់ងាររបស់ខ្លួននៅខាងក្រោមហើយឃើញសកម្មភាពណាមួយមិនស្របច្បាប់ជាការឃោសនា ឬជាការបង្ខិតបង្ខំណាមួយជូនព័តិមាន ឬ ប្តឹងមកគណកម្មាធិការរៀបចំការបោះឆ្នោតដើម្បីដោះស្រាយទាន់ពេលវេលា។ ចំពោះផ្លាកសញ្ញាគណបក្ស គណកម្មាធិការរៀបចំការបោះឆ្នោតមិនបានគិតថ្នាក់យកម៉ែត្រទៅវាស់នោះទេដូចដែលខាងយុវជនបានលើកឡើង ហើយឯកឧត្តមគិតថាប្រជាពលរដ្ឋបានគិតមកពីផ្ទះរួចហើយថាត្រូវបោះឆ្នោតជូនអ្នកណា គាត់មិនមែនសំរេចចិត្តដោយគ្រាន់តែបានឃើញ ផ្លាកសញ្ញាគណបក្សនៅពេលដែលគាត់ទៅបោះឆ្នោតមួយភ្លែតនោះទេ។ ខាង NICFEC ដែលបានលើកឡើងដែលថាមានការគូសលើ ប័ណ្ណព័តិមានឯកឧត្តមសូមជំរាបថាមិនមែនជាបញ្ហាអ្វីធំដុំទេព្រោះថាមានចលនា និង មានអ្នកយកចិត្តទុកដាក់ ទី១ ខាងគណកម្មាធិការជាតិរៀបចំបោះឆ្នោតមានប្រព័ន្ធត្រួតពិនិត្យថាតើប័ណ្ណព័តិមានបានទៅដល់ ដៃប្រជាពលរដ្ឋដែរឬអត់ ? ហើយ មេភូមិ ជាអ្នកចែកប័ណ្ណជាមួយគណកម្មាធិការជាតិរៀបចំបោះឆ្នោតជាមួយខាង NGO ប្រហែល៩00នាក់ ពេលចែកក្រុមខ្លះចែករួមគ្នា ក្រុមខ្លះចែកបែកគ្នាដូចនេះ ហើយទើបមានការត្រួតពិនិត្យខ្លះ ហើយដោយដឹងថាដល់ ឬ មិនដល់មានតែមេភូមិទេដែលដឹងច្បាស់ គជប ក៏មានការប្រយ័ត្នប្រយែងដែរក្នុងពេលចែកប័ណ្ណព័តិមានលើកទី១ ដោយសារមេឃុំដែលគាត់យកប័ណ្ណព័តិមានទៅទុកក្នុងហោប៉ៅ របស់គាត់ហើយប្រាប់ថាបាន

ចែកទៅប្រជាពលរដ្ឋហើយ ។ បញ្ហាដែលថាហាមមិនអោយចងបដា ឧទាហរណ៍ បើចងនៅកន្លែងទីសាធារណៈណាមួយគេហាម បើចងនៅទីសាធារណៈមួយដែលមានការយល់ព្រមមិនមានអ្នកណាទៅហាមឃាត់ទេ បើសិនជា គណកម្មាធិការឃុំរៀបចំការបោះឆ្នោតនៅឃាត់នោះមិនត្រឹមត្រូវទេ ករណីនេះមិនជាធំដុំអ្វីទេគ្រាន់តែជូនព័ត៌មានឡើងវិញ ។ នៅឃុំអ្វី ដែលយើងអប់រំសំខាន់នោះគឺអោយមានការប្រជុំប្រចាំសប្តាហ៍ និង ក្នុងករណីមានបញ្ហាសូមអោយប្រជុំគ្នាដោះស្រាយពីព្រោះថាមិនមែន អ្នកទាំងអស់នោះសុទ្ធតែចេះនិតិវិធីទាំងអស់ទេ ដូចនេះហើយបានជាចែកសៀវភៅ CD ថែមទៀតក្នុងករណីមិនយល់អាចទូរស័ព្ទមកសួរទៀត ។

លោក **ឱក សេរីសោភក្តិ** បានមានប្រសាសន៍ថា នៅខែ ឧសភា ទី ១៧ វិទ្យាស្ថាន CDRI នឹងរៀបចំសន្និសិទ្ធថ្នាក់ជាតិមួយដើម្បីសិក្សារៀនសូត្រអំពីលទ្ធផលនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់តាមរយៈ COPCEL ដែលយើងបានប្រជុំហើយយើងនឹងអញ្ជើញវាគ្មិនខាង គជប ខាងរដ្ឋាភិបាល ខាងអង្គការសង្គមស៊ីវិល ខាងគណបក្សនយោបាយ និង សហគមន៍អន្តរជាតិដើម្បីផ្តល់នូវការវាយតំលៃទៅលើយន្តនាការដែលយើងបានរៀបចំជាមួយគ្នា និង ទៅលើលទ្ធផល ដើម្បីទាញជាមេរៀនសំរាប់បំរើការបោះឆ្នោតនៅថ្នាក់ជាតិដែលនឹងកើតឡើងនៅខែកក្កដា ឆ្នាំ២០០៨ ខាងមុខនេះ ។